


# ឯកសារពិគ្រោះយោបល់សំរាប់ការអភិវឌ្ឍ គណបក្សនយោបាយ ភាគ២

## គោលការណ៍ណែនាំអំពីទំនាក់ទំនងសភា

# ADVISORY PAPERS ON POLITICAL PARTY DEVELOPMENT, Volume II

## GUIDELINES TO PARLIAMENTARY COMMUNICATIONS

Konrad
Adenauer
Stiftung

**Freedom, Justice and solidarity are the basic principles underlying the work of the Konrad-Adnauer-Stiftung (KAS). KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian-social, conservative and liberal traditions. His name is synonymous with the democratic reconstruction of Germany, the firm alignment of foreign policy with the trans atlantic community of values, the vision of a unified Europe and an orientation towards the social market economy. In our European and international cooperation with more than 70 offices abroad and projects in over 120 countries, we make a unique contribution to the promotion of democracy, the rule of law and a social market economy.**

Konrad
Adenauer
Stiftung

# ឯកសាពិគ្រោះយោបល់សម្រាប់ ការអភិវឌ្ឍគណបក្សនយោបាយ ភាគ២

## គោលការណ៍ណែនាំអំពីទំនាក់ទំនងសភា

Konrad
Adenauer
Stiftung

សេរីភាព យុត្តិធម៌ និងសាមគ្គី ជាគោលការណ៍ក្នុងការកំណត់សកម្មភាពរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) គឺជាមូលនិធិនយោបាយមួយ ដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយគណបក្សប្រជាធិបតេយ្យគ្រឹស្ត (Christian Democratic Union) របស់ប្រទេសអាល្លឺម៉ង់។ លោក ខុនរ៉ាដ អាដិនណៅអ៊ែរ (១៨៧៦-១៩៦៧) គឺជាសហស្ថាបនិកនៃគណបក្ស CDU និងជាអធិការបតីដំបូងគេបង្អស់ នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានបង្រួបបង្រួមពួកសង្គមគ្រឹស្តនិយម ពួកអភិរក្សនិយម និងពួកសេរីនិយមទាំងឡាយ។ កិត្តិនាមរបស់លោក មានន័យដូចគ្នាទៅនឹងការកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ការយល់ស្របគ្នាលើគោលនយោបាយការបរទេស ទៅនឹងគុណតម្លៃនៃសហគមន៍មហាសមុទ្រអាត្លង់ទិក ចក្ខុវិស័យនៃការបង្រួបបង្រួមអឺរ៉ុប និងការតម្រង់ទិសឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសង្គម។ KAS បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើស្ទួយលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសេដ្ឋកិច្ចទីផ្សារសង្គម នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប និងអន្តរជាតិ តាមរយៈការិយាល័យរបស់ខ្លួននៅបរទេស ច្រើនជាង៧០ការិយាល័យ និងមានគម្រោងនានា នៅក្នុងប្រទេសជាង ១២០ប្រទេស។

ការិយាល័យនៅកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៤។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរនៅកម្ពុជា បាននឹងកំពុងបំពេញការងាររបស់ខ្លួន ក្នុងវិស័យដូចតទៅ៖ កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ការពង្រឹងគណបក្សនយោបាយ និងសភា កំណែទម្រង់ច្បាប់ ការអភិវឌ្ឍប្រព័ន្ធឃោសនា ការអប់រំនយោបាយ និងសេដ្ឋកិច្ចទីផ្សារសង្គម ក៏ដូចជាការពិគ្រោះយោបល់ផ្នែកគោលនយោបាយការបរទេសផងដែរ។

# មាតិកា


អារម្ភកថា ........................................ ១

១. សេចក្តីផ្តើម ........................................ ៣

២. មុខងារទំនាក់ទំនងរបស់រដ្ឋបាលសភា ........................................ ៥

៣. ការចែកចាយព័ត៌មាន៖ ឧបករណ៍គន្លឹះ ........................................ ១០

៤. ទំនាក់ទំនងរបស់ (ក្រុម) គណបក្សនយោបាយនៅក្នុងសភា ........................................ ១៥

៥. ទំនាក់ទំនងរវាងអង្គភាពព័ត៌មានរបស់ក្រុមសមាជិកសភា
និងគណបក្សនយោបាយ ........................................ ២០

៦. ឧបករណ៍របស់អង្គភាពព័ត៌មាននយោបាយ ........................................ ២២

៧. ទំនាក់ទំនង/ទំនាក់ទំនងសាធារណៈនៃសមាជិកសភាម្នាក់ៗ ........................................ ២៤

៨. ការផ្លាស់ប្តូរព័ត៌មានរបស់សមាជិកសភាជាមួយនឹងគណបក្សនយោបាយ.... ២៧

៩. តួនាទីរបស់អ្នកនាំពាក្យគណបក្ស ........................................ ២៨

១០. ទំនាក់ទំនងផ្ទៃក្នុងជាមួយក្រុមនយោបាយ ........................................ ៣១

១១. ទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ........................................ ៣២

១២. ទំនាក់ទំនងសភាជាមួយស្ថាប័នខាងក្រៅ ........................................ ៣២

## អារម្ភកថា

បណ្តាប្រទេសប្រជាធិបតេយ្យអាស្រ័យសភា ជាទូទៅមានសមាសភាពច្រើន ដែលតម្រូវឲ្យមានដំណើរការទំនាក់ទំនងទៅវិញទៅមក។ ស្ថាប័នសំខាន់ៗនៅកម្ពុជាមានដូចជា រដ្ឋបាលសភា (សភាជាតិ) ដែលរួមមាន រដ្ឋសភាកម្ពុជា និងព្រឹទ្ធសភា ក្រុមគណបក្សនយោបាយ (Fractions) និងសមាជិកសភានីមួយៗ។ លើសពីនេះ ស្ថាប័នឯករាជ្យក៏មានឥទ្ធិពលលើដំណើរការប្រជាធិបតេយ្យនេះផងដែរ។ ស្ថាប័នទាំងនេះរួមមាន ស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននីតិបញ្ញត្តិថ្នាក់ក្រោមជាតិ ប្រព័ន្ធផ្សព្វផ្សាយ និងក្នុងករណីខ្លះ ក៏មានអង្គការក្នុងតំបន់ (ឧទាហរណ៍៖ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ដែលប្រទេសកម្ពុជាជាសមាជិក) ផងដែរ។

សមត្ថភាពរបស់ស្ថាប័នទាំងនេះក្នុងការធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ / សាធារណជន និងក្រុមសារព័ត៌មានប្រកបដោយតម្លាភាព ភាពត្រឹមត្រូវ និងភាពទៀតទាត់ពេលវេលា តាមរយៈមធ្យោបាយចែករំលែកផ្ទាល់ខ្លួន និងការភ្ជាប់ទំនាក់ទំនងបែបនេះ គឺជាធាតុផ្សំដ៏សំខាន់មួយរបស់ប្រទេសប្រជាធិបតេយ្យអាស្រ័យសភា ដែលទទួលបានជោគជ័យ។

គោលការណ៍ណែនាំទាំងនេះ ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់សមត្ថភាពរបស់បុគ្គលដែលទទួលខុសត្រូវផ្នែកទំនាក់ទំនងនៅក្នុងស្ថាប័នទាំងនេះ ដើម្បីធ្វើឲ្យការប្រាស្រ័យទាក់ទងកាន់តែប្រសើរជាមួយអ្នកបោះឆ្នោត និងសង្គមស៊ីវិលក្នុងបរិយាកាសផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ ដែលភាគច្រើនជះឥទ្ធិពលពីប្រព័ន្ធអ៊ីនធើណិត និងការរីកលូតលាស់នៃឧបករណ៍ផ្សព្វផ្សាយព័ត៌មានសង្គមនៅក្នុងមជ្ឈដ្ឋានសភា និងមជ្ឈដ្ឋានខាងក្រៅ។ លក្ខខណ្ឌប្រកួតប្រជែងរវាងរដ្ឋាភិបាល និងក្រុមឯករាជ្យផ្សេង

ទៀតក្នុងសង្គម កំពុងតែធ្វើឲ្យមានសមភាព។ ដោយសារភាពចាំបាច់ គោលការណ៍ណែនាំនេះត្រូវតែមានទាំងអព្យាក្រឹតភាព និងលក្ខណៈទូលំទូលាយ។

គោលការណ៍ណែនាំនេះមានគោលបំណងបង្កើត និងបង្កើនឧបករណ៍ និងនីតិវិធីដែលមានស្រាប់ តាមរយៈការប្រើប្រាស់បច្ចេកទេសទំនាក់ទំនងដែលអាចរកបានទាំងអស់។ ជាក់ស្តែង អ្វីដែលចាំបាច់ត្រូវធ្វើនោះ គឺការបង្កើនទំនាក់ទំនងជាមួយបុគ្គល សំខាន់ៗ ដើម្បីជានាអំពីការទទួលយកគោលនយោបាយ និងទិសដៅច្បាស់លាស់។ ទំនាក់ទំនងគឺជាស្នូលនៃអភិបាលកិច្ចល្អ។ គោលការណ៍ណែនាំនេះរួមមានទំនាក់ទំនងប្រាំវិស័យៈ

- មុខងារទំនាក់ទំនងរដ្ឋបាលសភា
- ទំនាក់ទំនងក្រុមគណបក្សនយោបាយ (Fraction)
- ទំនាក់ទំនងសមាជិកសភានីមួយៗ
- អ្នកនាំពាក្យរបស់រដ្ឋបាលសភា និងក្រុមគណបក្សនយោបាយ (Fraction) និងតួនាទីរបស់ពួកគេ
- ទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ដែលពាក់ព័ន្ធនឹងប្រទេសប្រជាធិបតេយ្យអាស្រ័យសភា។

ដោយពិចារណាអំពីសារៈសំខាន់ជាច្រើន នៃប្រព័ន្ធអ៊ីនធើណិត គេគួរតែយកចិត្តទុកដាក់ទៅលើតួនាទីរបស់អ៊ីនធើណិត។

**Alastair Carthew**
*ទីប្រឹក្សា*

# គោលការណ៍ណែនាំអំពីទំនាក់ទំនងសភា

## វិធីប្រតិបត្តិទំនាក់ទំនងសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយ ក្នុងបរិយាកាសសភាកម្ពុជា

## ១. សេចក្ដីផ្ដើម

សភាកម្ពុជារួមមានរដ្ឋសភា (សមាជិកត្រូវបានបោះឆ្នោតទៅតាមតំណាងសមាមាត្រ) និងព្រឹទ្ធសភា (សមាជិកបួននាក់ត្រូវបានចាត់តាំង និងសមាជិកផ្សេងទៀតត្រូវបានបោះឆ្នោតដោយក្រុមប្រឹក្សាឃុំ/សង្កាត់ ២៤ ខេត្តក្រុង)។ ជាទូទៅសាធារណជននៅលើពិភពលោកនេះ មិនសូវយល់ដឹងច្បាស់អំពីដំណើរការរបស់សភាប៉ុន្មានទេ ប៉ុន្តែពួកគេគឺជាធាតុផ្សំដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ដោយដើរតួនាទីសំខាន់ក្នុងការតាក់តែងច្បាប់ ការត្រួតពិនិត្យ អភិបាលកិច្ច និងការធ្វើជាតំណាង។

ប្រទេសកម្ពុជាវិញក៏ដូចគ្នាអញ្ចឹងដែរ។ ដោយសារតែមានតួនាទីសំខាន់ក្នុងសង្គម ការយកចិត្តទុកដាក់យ៉ាងច្រើនពីប្រព័ន្ធផ្សព្វផ្សាយ និងការរំពឹងទុកពីសំណាក់សាធារណជនទូទៅ សភាត្រូវបានរៀបចំឡើងបានយ៉ាងល្អ ដើម្បីប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការជួយបង្កើតមណ្ឌលសភា ដែលទទួលបានព័ត៌មាន និងមានការយល់ដឹងកាន់តែប្រសើរ។ ឧទាហរណ៍ រដ្ឋសភាមានអំណាចនីតិប្បញ្ញត្តិលើបញ្ហាសំខាន់ៗ ដូចជា គម្រោងថវិកា ពន្ធ ច្បាប់ សន្ធិសញ្ញាអន្តរជាតិ និងការបង្កើតរដ្ឋាភិបាល។ បញ្ហាសំខាន់ៗទាំងនេះ ត្រូវការឲ្យមានទំនាក់ទំនងប្រកបដោយសង្គតិភាព។ គណៈកម្មការសភា (គណៈកម្មាធិការ) ដែលធ្វើការពិចារណាលើការតាក់តែងច្បាប់ គឺជាមធ្យោបាយមួយផ្សេងទៀតសម្រាប់ទំនាក់ទំនងប្រភេទនេះ។ ដូច្នេះ ទំនាក់ទំនងច្បាស់លាស់ប្រកបដោយសង្គតិភាពនៅ

*...ទំនាក់ទំនងច្បាស់លាស់ប្រកបដោយសង្គតិភាពនៅគ្រប់មជ្ឈដ្ឋានសភាទាំងអស់ ដោយប្រើប្រាស់ឧបករណ៍ប្រភេទខុសៗគ្នា ដើម្បីបង្កើនចំណេះដឹងរបស់សាធារណជន អំពីដំណើរការសភានោះ នឹងជួយបង្កើនទំនុកចិត្តកាន់តែច្រើន ទៅលើលទ្ធិប្រជាធិបតេយ្យអាស្រ័យសភា នៅក្នុងប្រទេសកម្ពុជា។*

គ្រប់មជ្ឈដ្ឋានសភាទាំងអស់ ដោយប្រើប្រាស់ឧបករណ៍ប្រភេទ ខុសៗគ្នា ដើម្បីបង្កើនចំណេះដឹងរបស់សាធារណជន អំពីដំណើរការសភានោះ នឹងជួយបង្កើនទំនុកចិត្តកាន់តែច្រើន ទៅលើលទ្ធិប្រជាធិបតេយ្យអាស្រ័យសភា នៅក្នុងប្រទេសកម្ពុជា។

គណបក្សនយោបាយនានាមានតួនាទីស្រដៀងគ្នា ប៉ុន្តែរំលេចលក្ខណៈនយោបាយជាង។ គណបក្សនយោបាយនីមួយៗ ដែលមានតំណាងក្នុងសភា បានបង្កើតរចនាសម្ព័ន្ធ ទស្សនៈវិជ្ជា ដំណើរការ និងយុទ្ធសាស្ត្ររបស់ខ្លួន។ គណបក្សនយោបាយទាំងនេះ ក៏មានផ្នែកតូចៗនៅក្នុងគណបក្ស ដែលមានរបៀបវារៈរបស់ខ្លួនផងដែរ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣ នេះ មានអ្នកចូលរួមបោះឆ្នោត ៦៨% តិចជាងឆ្នាំ២០០៨ (៨១,៥%)។ បើទោះជាមានការធ្លាក់ចុះយ៉ាងនេះក៏ដោយ ប្រការសំខាន់នោះគឺ សាធារណជនកម្ពុជាត្រូវយល់ដឹងឲ្យបានច្រើន អំពីប្រព័ន្ធនយោបាយ និងប្រជាធិបតេយ្យអាស្រ័យសភា។ មនុស្សតិចណាស់ដែលនៅក្រៅមជ្ឈដ្ឋាននយោបាយ យល់ដឹងអំពីកិច្ចប្រតិបត្តិការផ្ទៃក្នុងរបស់គណបក្សនយោបាយ ដោយសារតែពួកគេមានទំនាក់ទំនងតែមួយគត់ដែលពិតប្រាកដ គឺតាមរយៈមធ្យោបាយចែករំលែកទំនាក់ទំនង ដែលគណបក្សនយោបាយប្រើប្រាស់។

*ទំនាក់ទំនងទៅវិញទៅមក ដែលប្រើប្រាស់ឧបករណ៍ទាំងអស់ ដែលអាចរកបាន (សព្វថ្ងៃមានដូចជាអ៊ីនធើណិត ដែលជាឧបករណ៍មួយដ៏សំខាន់បំផុត) ជាមួយនឹងក្រុមឯកភាពជាទាំងនេះ គួរតែជាផ្នែកមួយនៃដំណើរការសភា។*

សមាជិកសភានីមួយៗ ដែលជាសសរស្តម្ភទាំងបីនៃត្រីជនាភិបាល (រដ្ឋសភា ព្រឹទ្ធសភា និងសមាជិកសភា) ត្រូវធ្វើប្រតិបត្តិការជាលក្ខណៈបុគ្គលនៅថ្នាក់មូលដ្ឋាន ដើម្បីបំពេញតម្រូវការម្ចាស់ឆ្នោតរបស់ខ្លួន។ ពួកគេត្រូវប្រើប្រាស់បច្ចេកទេសទំនាក់ទំនងខុសៗគ្នា ដោយប្រើប្រាស់អ៊ីនធើណិតឲ្យបានច្រើន ប៉ុន្តែក៏ត្រូវរក្សាទំនាក់ទំនងផ្ទាល់ផងដែរ។

អ្នកនាំពាក្យគណបក្សនយោបាយ គឺជាអ្នកចេញមុខជាសាធារណៈជារៀងរាល់ថ្ងៃ តំណាងឲ្យគណបក្សនយោបាយលើបញ្ហា គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់សហគមន៍ទូទៅ។ នេះគឺជាតួនាទីជាន់ខ្ពស់ដ៏សំខាន់ក្នុងជួររដ្ឋាភិ-បាលទាំងឡាយ ដោយសារបុគ្គលនោះ ទទួលខុសត្រូវលើការតំណាងឲ្យក្រុម

គណបក្សនយោបាយរបស់ខ្លួន ប្រកបដោយភាពជឿជាក់ ការជឿទុកចិត្ត និង សង្គតិភាព។

ស្ថាប័នខាងក្រៅមជ្ឈដ្ឋានសភា អាចមានឥទ្ធិពលយ៉ាងខ្លាំងលើទស្សនៈរបស់សាធារណជន។ ក្រុមឯករាជ្យទាំងនេះរួមមានស្ថាប័នជាតិ សហជីព អង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការអន្តរជាតិ និងអង្គការក្នុងតំបន់។ ទំនាក់ទំនងទៅវិញទៅមក ដែលប្រើប្រាស់ឧបករណ៍ទាំងអស់ដែលអាចរកបាន (សព្វថ្ងៃមានដូចជា អ៊ីនធើណិត ដែលជាឧបករណ៍មួយដ៏សំខាន់បំផុត) ជាមួយនឹងក្រុមឯករាជ្យទាំងនេះ គួរតែជាផ្នែកមួយនៃដំណើរការសភា។

## ២. មុខងារទំនាក់ទំនងរបស់រដ្ឋបាលសភា

នៅប្រទេសកម្ពុជា លេខាធិការដ្ឋាននៃរដ្ឋសភា និងព្រឹទ្ធសភា អាចជាការិយាល័យដ៏សមរម្យ សម្រាប់ផ្តល់ការគាំទ្រផ្នែកទំនាក់ទំនងប្រកបដោយវិជ្ជាជីវៈ ទៅកាន់សមាជិកសភា (ផ្ទុយពីការិយាល័យសារព័ត៌មាននយោបាយ ដែលមានទំនាក់ទំនងជាមួយគណបក្សនយោបាយ)។ បញ្ហារដ្ឋបាលសភាក្នុងបណ្តាប្រទេសប្រជាធិបតេយ្យ នៅបស្ចិមប្រទេស ជាធម្មតាត្រូវបានដោះស្រាយតាមរយៈការិយាល័យប្រធានសភា ដែលត្រូវបានជ្រោមជ្រែងពីសំណាក់អង្គភាពផ្តល់សេវាសភា ដែលទទួលខុសត្រូវផ្នែករដ្ឋបាលធុរកិច្ច (កិច្ចប្រជុំសភា ប្រតិទិនច្បាប់។ល។) អគារសភា និងការិយាល័យនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី និងសមាជិកសភា។ បញ្ហានយោបាយ/គោលនយោបាយជាតិ ត្រូវដោះស្រាយដោយការិយាល័យនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី និងស្ថាប័នគណបក្សនយោបាយ។

មន្ត្រីសារព័ត៌មាននៃលេខាធិការដ្ឋាន ដែលធ្វើការនៅការិយាល័យរដ្ឋលេខាធិការដ្ឋាន ទទួលខុសត្រូវលើការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង ការផ្សព្វផ្សាយជាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មានតាមតម្រូវការ ទំនាក់ទំនងសាធារណៈរបស់សភា ការផ្តល់ព័ត៌មាន ការរក្សាប្រព័ន្ធទិន្នន័យនៃ ស្ថាប័នពាក់ព័ន្ធ ការបង្កើតទំនាក់ទំនងផ្ទៃក្នុង ការប្រមូល និងការចែកចាយព័ត៌មានពាក់ព័ន្ធ។

លេខាធិការដ្ឋាននេះ គួរតែទទួលខុសត្រូវលើការផ្តល់ប្រធានបទសមរម្យទៅឲ្យគណៈកម្មការ និងសមាជិកសភាទាំងអស់ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការផ្តល់ធាតុចូលទៅក្នុងការតាក់តែងច្បាប់ និងការបង្កើតគោលនយោបាយ។ ប្រការនេះអាចជួយបង្កើនការផ្សព្វផ្សាយព័ត៌មានទៅកាន់សាធារណជន តាមរយៈរដ្ឋសភា និងព្រឹទ្ធសភា ដោយផ្សព្វផ្សាយ និងអនុញ្ញាតឲ្យមានការចូលដល់សវនាការគណៈកម្មការ និងយន្តការសវនាការផ្សេងទៀត។ ការណ៍នេះ ក៏អាចជួយណែនាំសមាជិកសភា ឲ្យយល់ដឹងអំពីវិធីឆ្លើយតបទៅកាន់ម្ចាស់ឆ្នោតរបស់ខ្លួនឲ្យបានច្រើន ដោយផ្តល់ព័ត៌មានពាក់ព័ន្ធមកពីធនធានទំនាក់ទំនងដ៏ច្រើនរបស់សភា។

ដើម្បីទទួលបានព័ត៌មាន (មិនមែននយោបាយ) នេះ លេខាធិការដ្ឋានត្រូវធ្វើការជាមួយទីភ្នាក់ងារដូចជា បណ្ណាល័យសភា និងកាលប្បវត្តិ ដែលជាឃ្លាំងព័ត៌មានដ៏សំខាន់នៅក្នុងសភា។ ទីភ្នាក់ងារដទៃទៀត អាចរួមមានការិយាល័យរដ្ឋបាលកណ្តាលនៃរដ្ឋសភា និងព្រឹទ្ធសភា។ ព័ត៌មានទាំងនេះរួមមានៈ

*ដើម្បីទទួលបានព័ត៌មាន (មិនមែននយោបាយ) នេះ លេខាធិការដ្ឋានត្រូវធ្វើការជាមួយទីភ្នាក់ងារ ដូចជា បណ្ណាល័យសភា និងកាលប្បវត្តិ ដែលជាឃ្លាំងព័ត៌មានដ៏សំខាន់នៅក្នុងសភា។*

- ទិដ្ឋភាពទូទៅនៃសមាសភាព និងមុខងាររបស់សភា និងមណ្ឌលរបស់ខ្លួន
- សេចក្តីពណ៌នាអំពីតួនាទីជាក់លាក់នៃប្រព័ន្ធទ្វេសភានៅកម្ពុជា
- អត្ថបទពេញលេញស្តីពីបទបញ្ញាអចិន្ត្រៃយ៍ វិធាននៃនីតិវិធី និងឯកសារដែលចែងពីវិធានស្រដៀងគ្នា
- អត្ថបទអំពីធម្មនុញ្ញក្នុងប្រទេស
- បញ្ជីសភាថ្នាក់តំបន់ និងអន្តរជាតិ ដែលមានសភាកម្ពុជាជាសមាជិក
- បញ្ជីគណៈកម្មការ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត
- ទិដ្ឋភាពទូទៅនៃនីតិវិធីសភា
- សេចក្តីពន្យល់អំពីទម្លាប់បទបញ្ញានៃកិច្ចការក្នុងសភា
- ប្រវត្តិសង្ខេបរបស់ស្ថាប័ន
- អត្ថបទស្តីពីការចេញផ្សាយព័ត៌មានជាផ្លូវការរបស់សភា
- ដ្យាក្រាមនៃការរៀបចំអាសនៈក្នុងសភាប្រជុំពិភាក្សាដេញដោល

- របនាសម្ព័ន្ធនៃលេខាធិការដ្ឋាន និងឈ្មោះលេខាធិការ/អ្នកកត់ត្រា
- ព័ត៌មានជាក់ស្តែងអំពីការចូលទៅកាន់អគារសភា បណ្ណាល័យ និងកាលប្បវត្តិ។
- ការពិពណ៌នាអំពីស្ថាប័ន មុខងារ និងនីតិវិធីការងាររបស់សភា។
- ប្រតិទិននៃកិច្ចការរបស់សភា (ការប្រជុំសភា សវនាការគណៈកម្មការ)។
- ព័ត៌មានអំពីប្រវត្តិរបស់សភា។
- ព័ត៌មានអំពីច្បាប់ដែលកំពុងត្រូវបានអនុម័ត។
- ឈ្មោះមន្ត្រីដឹកនាំ (មេដឹកនាំគណបក្ស ប្រធានគណៈកម្មការ)។
- ព័ត៌មានជាភាសាជាតិ (ដោយមានជាភាសាអង់គ្លេសផងដែរ)។

## តួនាទីសំខាន់របស់អ្នកនាំពាក្យក្នុងរដ្ឋបាលសភា

សភាគួរមានមនុស្សម្នាក់ ដែលត្រូវបានចាត់តាំងឲ្យទទួលបន្ទុកបញ្ហាប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែមនុស្សម្នាក់នេះ មិនចាំបាច់មានលក្ខណសម្បត្តិដូចអ្នកនាំពាក្យគណបក្សនយោបាយទេ ដោយសារតែតួនាទីរបស់ពួកគេខុសគ្នា។ អ្នកនាំពាក្យសភាអាចបញ្ចេញមតិអំពីការងារនីតិប្បញ្ញត្តិ នីតិវិធី និងច្បាប់ ប៉ុន្តែតួនាទីរបស់អ្នកនាំពាក្យគណបក្សត្រូវមានសមាសធាតុគណបក្សច្រើនជាងនេះ។

នៅក្នុងករណីសភា អ្នកនាំពាក្យអាចជាមន្ត្រីសភាមួយរូប ដែលស័ក្តិសមម្នាក់ ដែលមានសមត្ថភាពដូចអ្នកនាំពាក្យរបស់គណបក្សដែរ (អាចជឿជាក់បាន ចាស់ទុំ មានបទពិសោធន៍ មានវោហាសាស្ត្រល្អ និងមានជំនាញសរសេរ) ជាជាងបុគ្គលដែលមានបទពិសោធន៍លើប្រព័ន្ធផ្សព្វផ្សាយច្រើន។

*...អ្នកនាំពាក្យអាចជាមន្ត្រីសភាមួយរូប ដែលស័ក្តិសមម្នាក់ ដែលមានសមត្ថភាពដូចអ្នកនាំពាក្យរបស់គណបក្សដែរ (អាចជឿជាក់បាន ចាស់ទុំ មានបទពិសោធន៍ មានវោហាសាស្ត្រល្អ និងមានជំនាញសរសេរ)*

អ្នកនាំពាក្យសភា គួរតែជាអ្នកត្រួតពិនិត្យលើប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ។ គាត់អាចធ្វើបែបនេះបានដោយៈ

- ធានាថាព័ត៌មាននៅលើគេហទំព័រមានលក្ខណៈពាក់ព័ន្ធ និងថ្មីៗ ឧទាហរណ៍ៈ ទិន្នន័យប្រវត្តិរបស់អ្នកតំណាងរាស្ត្រ និងសភា។ បញ្ជីសមាសភាពសភា ព័ត៌មានអំពីការបោះឆ្នោតកន្លងទៅ ព័ត៌មានអំពីសេចក្តីព្រាងច្បាប់។

- គ្រប់គ្រងវេទិកាពិភាក្សាតាមប្រព័ន្ធអ៊ិនធើណិត (បើសិនជាមាន) ដែលអ្នកប្រើប្រាស់អាចសួរសំណួរដល់សមាជិកសភាបាន។
- គ្រប់គ្រងការបោះពុម្ពផ្សាយ និងការចែកចាយសម្ភារព័ត៌មានជាក្រដាសរបស់សភា ឧទាហរណ៍៖ ដូចជាសៀវភៅផ្សព្វផ្សាយ សៀវភៅព័ត៌មាន ឯកសារពន្យល់ខ្លីៗ។
- ផ្លាស់ប្ដូរព័ត៌មានជាមួយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋសភា និងព្រឹទ្ធសភាអំពីការងារតាក់តែងច្បាប់។
- គ្រប់គ្រងកម្មវិធីទំនាក់ទំនងសាធារណៈរបស់សភា ឧទាហរណ៍៖ កំឡុងពេលបើកសភាឲ្យសាធារណជនចូលទស្សនា ទស្សនកិច្ចសាលារៀន ទស្សនកិច្ច VIP។
- បង្កើតទំនាក់ទំនងផ្ទៃក្នុងជាមួយបុគ្គលិក ឧទាហរណ៍៖ បណ្ដាញអ៊ីនត្រាណិត និងកិច្ចប្រជុំជាទៀងទាត់។
- រៀបចំព្រឹត្តិការណ៍សារព័ត៌មាន (សន្និសីទសារព័ត៌មាន) ពីពេលមួយទៅពេលមួយ។ នៅក្នុងករណីនេះ ប្រសិនបើមានបញ្ហាពាក់ព័ន្ធនឹងកិច្ចការសភាជាក់លាក់ណាមួយ គាត់អាចជូនភារកិច្ចនេះទៅថ្នាក់ដឹកនាំរបស់លេខាធិការដ្ឋាន។




*រូបភាព១៖ តារាងទំនាក់ទំនងអង្គភាពសភា/ក្រុមនយោបាយ/សារព័ត៌មាន*

## ៣. ការចែកចាយព័ត៌មាន៖ ឧបករណ៍គន្លឹះ

ដើម្បីធ្វើឲ្យកាន់តែមានភាពងាយស្រួលក្នុងការទទួលព័ត៌មានទាំងនេះ លេខាធិការដ្ឋានអាចពិចារណាលើមធ្យោបាយផ្សព្វផ្សាយមួយចំនួន។

*ដើម្បីធ្វើឲ្យកាន់តែមានភាពងាយស្រួលក្នុងការទទួលព័ត៌មានទាំងនេះ លេខាធិការដ្ឋានអាចពិចារណាលើមធ្យោបាយផ្សព្វផ្សាយមួយចំនួន។*

បច្ចុប្បន្ននេះ គេហទំព័រ គឺជាផ្នែកសំខាន់មួយ នៃទំនាក់ទំនងសភា។ ពួកគេធ្វើឲ្យព័ត៌មានដែលពាក់ព័ន្ធ ងាយស្រួលរក ងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងអាចគ្របដណ្តប់លើមុខវិជ្ជាជាច្រើននៅកន្លែងមជ្ឈការមួយ។ ឧទាហរណ៍៖ អ្នកសារព័ត៌មាន អ្នកវិភាគនយោបាយ បញ្ញវន្ត និងសាធារណជន អាចទទួលបានព័ត៌មានថ្មីៗបំផុតពីគេហទំព័រសភា។ គេហទំព័រនេះ គួរមានសមាសធាតុសំខាន់ៗដូចខាងក្រោម៖

- សេចក្តីពន្យល់អំពីនីតិវិធីបោះឆ្នោត (ប្រព័ន្ធបោះឆ្នោត កន្លែង/មណ្ឌលបោះឆ្នោត អ្នកបោះឆ្នោត អ្នកត្រូវគេបោះឆ្នោតឲ្យ លក្ខខណ្ឌក្នុងការជ្រើសរើសឲ្យឈរឈ្មោះ អ្នករៀបចំការបោះឆ្នោត)។
- លទ្ធផលពីការបោះឆ្នោតលើកមុនដោយបណ្តាញគណបក្ស និងមណ្ឌលបោះឆ្នោត។
- ការអប់រំអំពីសភា និងនីតិវិធីសភា។
- សំណួរដែលសួរជាញឹកញាប់ និងចម្លើយ។
- គេហទំព័រសំខាន់ៗដែលភ្ជាប់ទៅគេហទំព័រសភាដទៃទៀត។
- ព័ត៌មានអ្នកចូលទស្សនា។
- សមាសភាពបច្ចុប្បន្ននៃក្រុមគណបក្ស/ក្រុមនយោបាយ។
- ព័ត៌មានអំពីដំណើរការនីតិប្បញ្ញត្តិ។ ការពន្យល់អំពីដំណើរការ របៀបវារៈ បទប្បញ្ញត្តិ និងកាលវិភាគនៃសម័យប្រជុំបច្ចុប្បន្ន មូលដ្ឋានទិន្នន័យនៃច្បាប់ដែលត្រូវបានអនុម័ត ស្ថានភាពបច្ចុប្បន្ននៃការងារសភា (ឧទាហរណ៍៖ ប្រធានបទស្តីពីសេចក្តីព្រាងច្បាប់ ចំណងជើង កាលបរិច្ឆេទ មាតិកា)។

- ព័ត៌មានស្ដីពីមន្ត្រីដឹកនាំក្នុងសភា អំណាច និងបុព្វសិទ្ធិរបស់គាត់ ឈ្មោះអនុប្រធាន (បើសិនជាមាន) បញ្ជីឈ្មោះអតីតមន្ត្រីដឹកនាំក្នុងសភា ការប្រមូលសុន្ទរកថា និងបទអន្តរាគមន៍សាធារណៈ (បើសិនជាអាច)។
- ស្ថាប័នសភាពិសេស (គណៈកម្មការ អនុគណៈកម្មាធិការ)៖ បញ្ជីពេញលេញនៃស្ថាប័នទាំងនេះជាមួយនឹងតំណភ្ជាប់ (hyperlinks) ទៅកាន់គេហទំព័ររបស់ពួកគេ (បើសិនជាមាន) ក្រមប្រតិបត្តិ និងអាណត្តិរបស់ស្ថាប័ន ឈ្មោះសមាជិក ព័ត៌មានទាក់ទង កាលវិភាគកិច្ចប្រជុំ និងសវនាការដែលធ្វើឡើងដោយស្ថាប័នសភានីមួយៗ ការចេញផ្សាយសារព័ត៌មានទាក់ទងនឹងការងាររបស់ស្ថាប័ន និងទិន្នន័យប្រវត្តិស្ថាប័ននីមួយៗ។
- ការចែកចាយព័ត៌មានសភាទៅដល់ស្ថាប័នសភារបស់ប្រទេសដទៃទៀត ឧទាហរណ៍៖ បច្ចុប្បន្ន ការងារនេះអាចសម្រេចបានកាន់តែងាយស្រួល តាមរយៈអ៊ិនធើណិត។ គេអាចចែករំលែកតាមរយៈក្រុមនៅក្នុងគេហទំព័រមួយ គេហទំព័រភ្ជាប់ទៅខាងក្រៅរបស់សភា គណបក្សនយោបាយ និងស្ថាប័ននានានៅក្នុងប្រទេសដទៃទៀត។ គេហទំព័រភ្ជាប់ទាំងនេះ គួររួមបញ្ចូលគេហទំព័ររបស់ប្រធានាធិបតីរបស់ប្រទេសនោះ រដ្ឋាភិបាល និងតុលាការកំពូល និងតុលាការធម្មនុញ្ញ (បើសិនជាមាន) គេហទំព័រសភាដទៃទៀត (ជាពិសេសសភាដែលមានប្រព័ន្ធទ្វេសភា ដែលស្រដៀងនឹងសភាប្រទេសកម្ពុជា) ព្រឹទ្ធសភា ស្ថាប័ននយោបាយអន្តរសភា ស្ថាប័នសភាក្នុងតំបន់ គណបក្សនយោបាយជាតិសមាជិកសភាម្នាក់ៗ (បើសិនជាមាន) និងក្រសួងនីមួយៗ និងទីភ្នាក់ងារជាតិដទៃទៀត។ សមាជិកភាពអាស៊ានរបស់កម្ពុជា (សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍) និងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ក្នុងឆ្នាំ ២០១៥ ធ្វើឲ្យទំនាក់ទំនងអន្តរប្រទេសកាន់តែមានសារៈសំខាន់ជាងមុន។
- លេខាធិការដ្ឋានគួរមានការទទួលខុសត្រូវរួមលើខ្លឹមសារក្នុងគេហទំព័រ ប៉ុន្តែនៅក្នុងករណីខ្លះខ្លឹមសារក្នុងគេហទំព័រអាចត្រូវភាគីទីពបង្កើតឡើង ដូចជាវេទិកាអ៊ិនធើណិត និងប្លក់ (blogs)។

- ការធ្វើបច្ចុប្បន្នកម្មជាទៀងទាត់លើព័ត៌មានសភាដែលពាក់ព័ន្ធគឺសំខាន់។ កិច្ចការនេះអាចសម្រេចបាន តាមរយៈការពន្យល់ជាគោលៗអំពីដំណើរការនីតិប្បញ្ញត្តិ។ របៀបវារៈនីតិប្បញ្ញត្តិ និងកាលវិភាគអំពីសម័យប្រជុំបច្ចុប្បន្ន មូលដ្ឋានទិន្នន័យដែលអាចស្វែងរកបានស្ដីពីច្បាប់នីតិប្បញ្ញត្តិ ដែលត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិបច្ចុប្បន្ន ស្ថានភាពការងារសភាបច្ចុប្បន្ន តាមរយៈចំនួនសេចក្ដីព្រាងច្បាប់ ប្រធានបទ ចំណងជើង កាលបរិច្ឆេទ លេខកូដឯកសារ ស្ថាប័នសភា។ល។ មូលដ្ឋានទិន្នន័យ ដែលអាចស្វែងរកបានស្ដីពីរបាយការណ៍គណៈកម្មការធិការ កំណត់ត្រា សវនាការ និងការបោះឆ្នោត។ កំណត់ត្រាសង្ខេបនៃកិច្ចប្រជុំ/កិច្ចពិភាក្សាដេញដោលក្នុងសភា។ ផ្នែកមួយដែលផ្ដោតទៅលើសំណួរដែលដាក់ជូនដល់ផ្នែកប្រតិបត្តិ សទ្ទានុក្រមនីតិវិធីសភា និង (បើសិនជាអាច) គេហទំព័រវីដេអូ និងសំឡេងដែលផ្សាយពីសម័យប្រជុំសភា។

ខាងក្រោមនេះ គឺជាតំណភ្ជាប់ទៅកាន់គេហទំព័រសភាមួយចំនួន នៅក្នុងយុត្តាធិការដទៃទៀត។

- ប្រទេសអូស្ត្រាលី៖ http://www.aph.gov.au/About_Parliament/House_of_Representatives
- ប្រទេសសិង្ហបុរី៖ http://www.parliament.gov.sg/
- ប្រទេសថៃ៖ http://www.parliament.go.th/ewtadmin/ewt/parliament_parcy/main.php?filename=parliament2554
- ប្រទេសកាណាដា៖ http://www.parl.gc.ca/Default.aspx?Language=E

*បណ្ដាញព័ត៌មានសង្គមដើរតួនាទីកាន់តែសំខាន់ នៅក្នុងប្រទេសប្រជាធិបតេយ្យអាស្រ័យសភា។*

បណ្ដាញព័ត៌មានសង្គមដើរតួនាទីកាន់តែសំខាន់ នៅក្នុងប្រទេសប្រជាធិបតេយ្យអាស្រ័យសភា។ លេខាធិការដ្ឋានគួរតែជាផ្នែកមួយនៃប្រព័ន្ធផ្សព្វផ្សាយសង្គមតាមរយៈប្រព័ន្ធផ្សព្វផ្សាយ Facebook ដោយផ្ដល់នូវព័ត៌មានពាក់ព័ន្ធ (ដូចខាងលើ) និងអនុញ្ញាតឲ្យសាធារណជនផ្ដល់មតិកែលម្អដោយផ្ទាល់ ទៅកាន់សភាវិញ។ ប្រព័ន្ធសង្គម Twitter ក៏អាចប្រើប្រាស់ផងដែរ ឧទាហរណ៍ដើម្បីចែករំលែកព័ត៌មានថ្មីៗ និងបង្កើតឲ្យមានអ្នកគាំទ្រ។

លេខាធិការដ្ឋានត្រូវតែមានកញ្ចប់ព័ត៌មានពេញលេញមួយ ដែលរួមបញ្ចូលព័ត៌មានខាងលើមួយផ្នែកធំ តាមរយៈការផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយ សៀវភៅស្តើង "បន្ទះផ្ទុកទិន្នន័យ (Flash stick)" សម្រាប់ការប្រើប្រាស់កុំព្យូទ័រ ព័ត៌មានទំនាក់ទំនង ការចូលដល់បណ្ណាល័យរូបភាព/វីដេអូ និងសូម្បីតែអនុស្សាវរីយ៍តូចតាចក៏ដោយ។

ការបោះពុម្ពផ្សាយរបស់សភាអាចរកបាននៅលើគេហទំព័រ នៅបញ្ជររបស់សភា តាមរយៈស្តង់សៀវភៅរបស់សភា ការិយាល័យតំណាងរាស្ត្រ និងការិយាល័យគណៈកម្មការ។ ការបោះពុម្ពផ្សាយទាំងនេះមានសារៈប្រយោជន៍ណាស់សម្រាប់អ្នកស្រាវជ្រាវ អ្នកសិក្សា។ល។ ជាពិសេស បើសិនបើពួកគេមិនមានប្រព័ន្ធអ៊ីនធើណិតប្រើប្រាស់ ឬក៏ពួកគេរស់នៅក្រៅរាជធានី។ បញ្ជីឯកសារ និងការបោះផ្សាយដែលមាននៅពេលបច្ចុប្បន្ននេះ អាចត្រូវបានបង្ហោះនៅលើ គេហទំព័រ (ការទាញយក PDF ដោយឥតគិតថ្លៃ)។ ព័ត៌មានអំពីរបៀបទទួលបានឯកសារទាំងនេះ និងសេវាបញ្ជាផ្ទាល់តាមអ៊ីនធើណិត គឺសុទ្ធតែជាមធ្យោបាយដើម្បីផ្សព្វផ្សាយឯកសារបោះពុម្ពទាំងនេះ។

ខិត្តប័ណ្ណ សៀវភៅស្តើង និង"កាសែត" សភា គួរត្រូវបានផលិតឡើងដោយលេខាធិការដ្ឋាន និងដាក់ឲ្យប្រើប្រាស់នៅសភាដោយផ្ទាល់ តាមរយៈបញ្ជរសៀវភៅរបស់សភា ការិយាល័យតំណាងរាស្ត្រ និងអ៊ីនធើណិត។ ក្នុងន័យនេះ អង្គភាពព័ត៌មាននយោបាយគួរធ្វើការជិតស្និទ្ធជាមួយបណ្ណាល័យសភា ដែលជាឃ្លាំងស្តុកឯកសារសំខាន់ៗ នៅក្នុងសភាភាគច្រើន។

ការផ្សាយបន្តផ្ទាល់តាមកញ្ចក់ទូរទស្សន៍ ស្តីពីការប្រជុំសភាជួយសាធារណជនឲ្យយល់ដឹងអំពីដំណើរការរបស់សភា ទោះបីជាអ្នកនយោបាយខ្លះ មិនចង់ឲ្យមានការផ្សាយបន្តផ្ទាល់នេះក្តី។ វាអាចនឹងត្រូវការឲ្យមានស្ថានីយទូរទស្សន៍ពិសេសមួយរបស់សភា ដែលបង្កើតឡើងក្រោមយុត្តាធិការរបស់អង្គភាពព័ត៌មាននយោបាយ (PPU's)។ ចាំបាច់មានអ្នកអត្ថាធិប្បាយ/អ្នកកាសែត ដែលមានបទពិសោធន៍ ដើម្បីពន្យល់អំពីដំណើរការ និងដាក់ការពិភាក្សាដេញដោលនៅក្នុងបរិបទ

*ចាំបាច់មានអ្នកអត្ថាធិប្បាយ/អ្នកការសែតដែលមានបទពិសោធន៍ដើម្បីពន្យល់អំពីដំណើរការ និងដាក់ការពិភាក្សាដេញដោលនៅក្នុងបរិបទសភា។*

សភា។

ការកែសម្រួលការផ្សាយបន្តផ្ទាល់តាមកញ្ចក់ទូរទស្សន៍ស្រដៀងគ្នានេះ ដែលពន្យល់អំពីសេចក្តីសម្រេចរបស់សភា បរិបទ សារតារ តួអង្គពាក់ព័ន្ធ និងផលប៉ះពាល់លើសាធារណជន អាចធ្វើទៅបានតាមរយៈអង្គភាពព័ត៌មាននយោបាយ។

ទស្សនកិច្ចទៅកាន់សភាដែលរៀបចំឡើងដោយលេខាធិការដ្ឋាន និងការិយាល័យសភា (រួមមានតំណាងរាស្ត្រនីមួយៗ នៅក្នុងការិយាល័យរបស់ពួកគេ) ជួយធ្វើឲ្យសាធារណជនមាន "អារម្មណ៍" កាន់តែប្រសើរឡើង អំពីការងារនិងដំណើរការរបស់តំណាងរាស្ត្រ ដែលពួកគេបានបោះឆ្នោតឲ្យ។ ទាំងនេះផ្តល់នូវអត្ថប្រយោជន៍ដ៏មានតម្លៃជាពិសេសសម្រាប់អប់រំសិស្សានុសិស្ស។ បញ្ជរដែលផ្តល់ព័ត៌មានពាក់ព័ន្ធអាចនឹងជួយផ្សព្វផ្សាយព័ត៌មានបន្ថែមទៀត។ លេខាធិការដ្ឋានគួរតែទទួលខុសត្រូវលើការរៀបចំ អំឡុងពេលបើកឲ្យទស្សនកិច្ចនេះ។

កម្មវិធី "ជួបជាមួយតំណាងរាស្ត្ររបស់អ្នក" ដែលរៀបចំឡើងយ៉ាងតិចពីរដងក្នុងមួយឆ្នាំ នឹងបង្ហាញអំពីជ្រុងមួយនៃលក្ខណៈរបស់ "មនុស្ស" ក្នុងនាមជាតំណាងរាស្ត្រ ដើម្បីឲ្យសាធារណជនបានយល់ដឹង។ នៅថ្ងៃនោះដែរអាចមានទស្សនកិច្ចជុំវិញសភា ការពិសាអាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន ក្នុងសភា ការជួបជាមួយមន្ត្រីសភា ទស្សនកិច្ចទៅកាន់សភាពិភាក្សាដេញដោល និងកិច្ចពិភាក្សាស្តីពីជីវិតជាតំណាងរាស្ត្រ ទាំងនេះត្រូវផ្សព្វផ្សាយដោយសេចក្តីប្រកាសព័ត៌មាន សៀវភៅស្តើង និងកញ្ចប់ព័ត៌មាន/ការអប់រំ។

ជូនកាល ការផ្តល់ព័ត៌មានឲ្យប្រព័ន្ធផ្សព្វផ្សាយអំពីដំណើរការសភាអាចមានភាពចាំបាច់។ អង្គភាពព័ត៌មាននយោបាយគួរតែរៀបចំការផ្តល់ព័ត៌មានទាំងនេះ ទោះបីជាអ្នកនាំពាក្យសម្រាប់ការផ្តល់ព័ត៌មានទាំងនេះ អាចតម្រូវឲ្យជាអ្នកជំនាញផ្នែកសភាដែលមានការគោរព ឬជាបុគ្គលម្នាក់ដែលស្រដៀងគ្នាទៅនឹងប្រធានសភា។ ការផ្តល់ព័ត៌មានទាំងនេះអាចកម្រនឹងកើតឡើងណាស់ (ដូចក្នុងករណីនៃការពន្យល់ពីសេចក្តីសម្រេចជាក់លាក់ ដែលមានការចម្រូងចម្រាសនៅក្នុងសភា) ឬជាញឹកញាប់ (ពន្យល់ពីបញ្ហាដែលកំពុងជួបប្រទះ ដែលតម្រូវឲ្យមាន

ការពិចារណាពីសភាជាន់ខ្ពស់ ដែលមានឥទ្ធិពលទៅលើស្ថាប័ន។ បញ្ហាគោលនយោបាយពាក់ព័ន្ធនឹងវិធីសាស្រ្ត និងយុទ្ធសាស្រ្តនយោបាយគួរតែជាតួនាទីរបស់គណបក្សនយោបាយក្នុងការដោះស្រាយ)។

## ៤. ទំនាក់ទំនងរបស់ (ក្រុម) គណបក្សនយោបាយនៅក្នុងសភា

ក្រុមគណបក្សនយោបាយទាំងអស់ប្រើប្រាស់អង្គភាពព័ត៌មាន (PPU សម្រាប់គោលការណ៍ណែនាំទាំងនេះ ប៉ុន្តែគេក៏អាចស្គាល់អង្គភាពទាំងនេះបានតាមរយៈឈ្មោះផ្សេងទៀត) ឲ្យដើរតួនាទីទំនាក់ទំនងផ្នែកនយោបាយ។ ព័ត៌មានរបស់អង្គភាពទាំងនេះ ខុសប្លែកពីព័ត៌មានរបស់អង្គភាពរដ្ឋបាលសភា ពីព្រោះវាពាក់ព័ន្ធទៅនឹងគោលនយោបាយ យុទ្ធសាស្រ្ត យុទ្ធវិធី ការទាក់ទាញរកសំឡេងឆ្នោត (ក្នុងករណីខ្លះ) និងជាទូទៅ ទំនាក់ទំនងសាធារណៈរបស់ក្រុមគណបក្សនយោបាយ ដែលពួកគេពេញចិត្ត។ ក្រុមគោលដៅចម្បងរបស់ PPU គឺប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ៊ីនធើណិត។

ដើម្បីដាក់បញ្ចូលតួនាទីរបស់ក្រុមគណបក្សនយោបាយ PPU ចូលទៅក្នុងបរិបទនេះ ប្រការសំខាន់នោះគឺត្រូវដឹងថា តើក្រុមគណបក្សនយោបាយជាអ្វី។ ពេលខ្លះក្រុមបែបនេះត្រូវបានហៅថា ក្រុមសមាជិកសភារបស់បក្ស ដែលដាច់ដោយឡែកពីក្រុមចាត់តាំងរបស់បក្ស។ ជាញឹកញាប់គេគិតថា វាមានសារៈសំខាន់ណាស់ ដែលសមាជិកសភា (ជាប់ឆ្នោត) មិនទទួលយកការណែនាំពីមន្រ្តីបក្ស (មិនជាប់ឆ្នោត) ដែលមានចំនួនច្រើនជាង។ ទម្រង់នៃការបង្កើតក្រុមតំណាងរាស្រ្តនេះ ជាទូទៅមាននៅក្នុងប្រទេសអាល្លឺម៉ង់ (ដែលហៅការបង្កើតក្រុមទាំងនេះថា Fractions) ប្រទេសអូស្រ្តាលី ប្រទេសអ៊ីតាលី ប្រទេសអូទ្រីស និងប្រទេសផ្សេងៗទៀត។ នៅសហភាពអឺរ៉ុប ក្រុមនយោបាយដូចជា សភាប្រជាជនអឺរ៉ុប (European People's Parliament) ជាដើម គឺជាក្រុមចម្រុះនៃអ្នកនយោបាយដែលមានចិត្តគំនិតដូចគ្នា ដែលមកពីប្រទេសផ្សេងៗ។ ការបង្កើតក្រុមតំណាងរាស្រ្តនេះ អាចធ្វើឲ្យសមាជិកសភាធ្វើការរួមគ្នាដើម្បីសម្រេចបាននូវ

គោលដៅតែមួយ បន្តអនុវត្តរបៀបវារៈគោលនយោបាយដែលមានការឯកភាពពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងសភា និងដើម្បីដឹកនាំប្រទេសជាតិប្រសិនបើស្ថិតក្នុងជួររដ្ឋាភិបាល។ អាសនៈច្រើន ក៏មានសំឡេងច្រើនតាមនោះដែរ។ ក្រុមនយោបាយនេះមានជំហររឹងមាំខ្លាំងជាងដើម្បីកំណត់តែងតាំងគណៈកម្មាធិការ (គណៈកម្មការ) ដើម្បីគ្រប់គ្រងនីតិបញ្ញត្តិ។ តាមរយៈចំនួននិងអំណាចបោះឆ្នោតរបស់ខ្លួន ក្រុមនយោបាយនេះ អាចនឹងទទួលបានអំណាចច្រើនជាងមុនតាមរយៈគណៈកម្មាធិការ និងតាមរយៈការបោះឆ្នោតជាប្លុកនៅក្នុងសភាផងដែរ។ នៅក្នុងប្រទេសជាច្រើន គណបក្សកាន់អំណាចអាចមានក្រុមសមាជិកសភាមួយរូប ឬច្រើនរូប នៅក្នុងរដ្ឋាភិបាលចម្រុះ ដោយក្រុមនីមួយៗប្រកាន់ខ្ជាប់មនោគមវិជ្ជា និងរបៀបវារៈគោលនយោបាយផ្ទាល់ខ្លួន ប៉ុន្តែធ្វើការសម្របសម្រួលលើបញ្ហាច្បាប់មួយចំនួន ដើម្បីរក្សាបានស្ថិរភាពរបស់រដ្ឋាភិបាល។ នៅក្នុងសភា គណបក្សនយោបាយនានានឹងរក្សាគម្លាតឃ្លាតពីគ្នា ហើយបោះឆ្នោតជ្រើសរើសមេដឹកនាំរបស់ខ្លួន។ រដ្ឋាភិបាលចម្រុះគឺជាការបង្កលក្ខណៈងាយស្រួលផ្នែកនយោបាយ ប៉ុន្តែមិនមែនជាការច្របាច់បញ្ចូលគ្នាផ្នែកគោលនយោបាយឡើយ។ ខាងក្រោមនេះគឺជាការបែងចែកក្រុមគណបក្សនយោបាយក្នុងអង្គនីតិបញ្ញត្តិថ្នាក់ក្រោមនៅប្រទេសអាល្លឺម៉ង់ក្នុងឆ្នាំ២០១១ (German Bundestag)។ ក្រុមនីមួយៗ មានការិយាល័យទំនាក់ទំនង និងទីប្រឹក្សាផ្ទាល់ខ្លួន។ ពួកគេទាំងអស់ជាផ្នែកមួយនៃសភា ប៉ុន្តែបន្តអនុវត្តតាមរបៀបវារៈគោលនយោបាយរបស់ខ្លួន។







(អាសនៈបន្ថែមនឹងមាននៅពេលដែលគណបក្សមួយទទួលបានអាសនៈតិចជាងសន្លឹកឆ្នោតដែលគណបក្សនេះឈ្នះតាមរយៈសន្លឹកឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោត ដែលបង្កើតជា "អាសនៈបន្ថែម" (សម្រាប់សន្លឹកឆ្នោតដែលបាត់) ហើយអាសនៈនឹងនៅតែជារបស់គណបក្សនេះ។)

*រូបភាព២៖ ការបែងចែកអាសនៈនៅក្នុងការបោះឆ្នោតលើកទី១៧ នៅក្នុងប្រទេសអាល្លឺម៉ង់ បន្ថែមព័ត៌មានចុងក្រោយនៅខែមិថុនា ឆ្នាំ២០១១*

*(សូមកត់សម្គាល់ថា៖ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ ការបែងចែកអាសនៈត្រូវបានផ្លាស់ប្តូរ៖ CDU/CSU៖ ៣១១ SPD៖ ១៩៣ Linke (Left Party)៖ ៦៤ Die Gruenen (The Greens)៖ ៦៣ FDP៖ មិនមាន*

សភាជាន់ទាប (House of Commons) របស់អង់គ្លេស ត្រូវបានចាត់ទុកជា "មាតាសភា" (mother of Parliaments)។ សភាជាន់ទាបរបស់អង់គ្លេសច្រើនជាក្រុមគណបក្សអភិរក្សនិយម (Conservative Party) រីឯគណបក្សប្រជាធិបតេយ្យសេរីនិយមវិញ (Liberal Democrats) មានចំនួនតិចតួចតែប៉ុណ្ណោះ។ គណបក្សប្រឆាំងដ៏ធំគឺគណបក្សពលករ (Labor Party)។ ក្នុងនោះ

ក៏មានសមាជិកសភាឯករាជ្យមួយចំនួនផងដែរ។ ក្រុមទាំងនេះត្រូវអង្គុយទល់មុខគ្នាតាមជួរកៅអីក្នុងសភាដែលមានប្រធានសភាជាអ្នកគ្រប់គ្រង។



*សភាជាន់ទាបរបស់អង់គ្លេស។ ក្រុមគណបក្សនយោបាយមានតែពីរប៉ុណ្ណោះ គឺក្រុមអភិរក្សនិយមរបស់រដ្ឋាភិបាលនៅខាងឆ្វេងដៃ ក្រុមគណបក្សពលករនៅខាងស្តាំដៃជាមួយគណបក្សប្រជាធិបតេយ្យសេរីនិយម ដែលជាដៃគូរដ្ឋាភិបាលចម្រុះវ័យក្មេងរបស់ក្រុមអភិរក្សនិយមដែលស្ថិតនៅកណ្តាល។ ទិដ្ឋភាពនេះគឺអង្គុយបែរមុខទៅប្រធានសភា។*

*ក្រុមសភាបន្តរបៀបវារៈ គោលនយោបាយដែលព្រមព្រៀង ទទួលបានពីកិច្ច ពិភាក្សាដេញដោល និងធាតុចូលដែលបានពីសមាជិកនៃគណបក្សនយោបាយនៅក្នុងសភាទូទៅ*

ជាធម្មតា ក្រុមសមាជិកសភាសហការគ្នាដើម្បីបម្រើឲ្យមេដឹកនាំតែមួយ ដែលស្ទើរតែគ្រប់ពេល ត្រូវបានជ្រើសរើសចេញពីសមាជិកពេញសិទ្ធិនៃគណបក្សនយោបាយរបស់ពួកគេ ដើម្បីដឹកនាំក្រុមនៅក្នុងអង្គនីតិបញ្ញត្តិ (សភា)។ មេដឹកនាំជាធម្មតាទទួលបានការគាំទ្រពី "ប្រធានក្រុមតំណាងរាស្ត្រ" ម្នាក់ ឬច្រើននាក់ ដែលមានតួនាទីរក្សានិងពង្រឹងវិន័យរបស់បក្ស។ នៅក្នុងយុត្តាធិការភាគច្រើន ក្រុមសមាជិកសភានឹងធ្វើការបោះឆ្នោតទៅតាមគោលនយោបាយបក្ស ប៉ុន្តែក្នុងករណីពិសេស "ការបោះឆ្នោតដោយមនសិការ" លើបញ្ហាសង្គមសំខាន់ណាមួយ (ដូច

ជាការរម្លូតកូន ការគ្រប់គ្រងកាំភ្លើងជាដើម) នឹងអនុញ្ញាតឲ្យសមាជិកសភាបោះឆ្នោតទៅតាមមនសិការរបស់ខ្លួន។

ក្រុមសភាបន្តរបៀបវារៈគោលនយោបាយដែលព្រមព្រៀង ទទួលបានពីកិច្ចពិភាក្សាដេញដោល និងធាតុចូលដែលបានពីសមាជិកនៃគណបក្សនយោបាយនៅក្នុងសភាទូទៅ តាមរយៈសន្និសីទបន្តបន្ទាប់សម្រាប់ផ្តល់ព័ត៌មានដល់សន្និសីទមួយរបស់បក្ស ហើយបញ្ហាគោលនយោបាយក៏ត្រូវបានអនុម័តនៅពេលនោះដែរ។ បន្ទាប់មកក្រុមសមាជិកសភាបន្តអនុវត្តរបៀបវារៈរបស់ខ្លួន នៅក្នុងសភាតាមរយៈការដាក់ចេញនូវច្បាប់ និងការស្តិតក្នុងសំឡេងភាគច្រើន (ប្រសិនបើមកពីគណបក្សកាន់អំណាច) ក្នុងជួរគណៈកម្មាធិការ នៅពេលទទួលសារណាពីសាធារណជនទាក់ទងនឹងបញ្ហាច្បាប់។

ទំនាក់ទំនងជាមួយក្រុមគោលដៅសំខាន់ៗ (ប្រព័ន្ធផ្សព្វផ្សាយ សាធារណជនស្ថាប័នជាតិ) គឺជាមុខងារដ៏សំខាន់មួយនៅក្នុងក្រុមនយោបាយ។ ជានិច្ចជាកាលក្រុមនេះត្រូវតែផ្តល់ព័ត៌មានត្រឹមត្រូវគួរឲ្យជឿទុកចិត្តដល់អ្នកទាំងនោះ ពេលខ្លះតាមរយៈអ្នកនាំពាក្យរបស់ខ្លួនដោយផ្ទាល់ (ការធ្វើបទសម្ភាសន៍ សន្និសីទកាសែត ការចែកចាយសេចក្តីប្រកាសព័ត៌មាន ការធ្វើបទបង្ហាញសង្ខេបជាលក្ខណៈឯកជន) គេហទំព័រ ទំព័រហ្វេសប៊ុកនិងសុន្ទរកថារបស់បក្ស (ជាធម្មតាប្រធានបក្សទទួលខុសត្រូវចំពោះសេចក្តីប្រកាសសំខាន់ៗ)។ ព័ត៌មានក៏អាចផ្តល់ឲ្យផងដែរតាមរយៈសេចក្តីប្រកាសក្នុងសភា។

## តួនាទីនិងមុខងារសំខាន់របស់ប្រធាន/មេដឹកនាំក្រុមនយោបាយ

ប្រធាន/មេដឹកនាំក្រុមនយោបាយ ដែលជាសមាជិកសភាក្នុងឆាកនយោបាយ ឬជាប្រធានបក្ស គួរតែធ្វើជាអ្នកនាំពាក្យផ្លូវការទៅតាមកាលៈទេសៈជាក់ស្តែង។ ក្នុងករណីខ្លះ អ្នកនាំពាក្យអាចជានាយករដ្ឋមន្ត្រី ដើម្បីឲ្យមានឥទ្ធិពលនិងការជឿទុកចិត្ត។ នៅពេលធ្វើសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីសំខាន់ៗ ដែលចាំបាច់ត្រូវការចំណេះដឹងច្បាស់លាស់អំពីបញ្ហានានា រដ្ឋមន្ត្រីក៏អាចជាអ្នកនាំពាក្យផងដែរ។ អ្នក

ដឹកនាំទទួលបន្ទុកលើការរៀបចំបក្ស អាចធ្វើជាអ្នកដឹកនាំបានសម្រាប់បញ្ហាបក្សនានា ។

អ្នកនាំពាក្យដែលទទួលបានការចាត់តាំងពីមេដឹកនាំក្រុមនយោបាយ (ដូចបានពិភាក្សាខាងលើ) អាចជាអ្នកគ្រប់គ្រងដោះស្រាយលើការឆ្លើយតបសំនួរប្រចាំថ្ងៃរបស់ប្រព័ន្ធផ្សព្វផ្សាយ ធ្វើសេចក្តីប្រកាសតាមទម្លាប់ និងដឹកនាំព្រឹត្តិការណ៍នានា។ ចំណុចដែលខុសគ្នានោះគឺនៅត្រង់ថា អ្នកនាំពាក្យ ដែលជាអ្នកនយោបាយមានវោហាសាស្ត្រនយោបាយច្រើនជាងអ្នកនាំពាក្យដែលត្រូវបានចាត់តាំង ហើយការអត្ថាធិប្បាយរបស់ពួកគេ គួរតែរក្សាបាននូវអព្យាក្រឹតភាពតាមដែលអាចធ្វើទៅបាន ដើម្បីទទួលបានការជឿទុកចិត្តពីប្រព័ន្ធផ្សព្វផ្សាយ។ អ្នកនាំពាក្យអាចប្រើប្រាស់គ្រប់វិធីសាស្ត្រទាំងអស់ ដែលបានបង្ហាញនៅក្នុងគោលការណ៍ណែនាំមុនៗ។

## ៤. ទំនាក់ទំនងរវាងអង្គភាពព័ត៌មានរបស់ក្រុមសមាជិកសភា និងគណបក្សនយោបាយ

វាមានសារៈសំខាន់ណាស់ ក្នុងបែងចែកភាពខុសប្លែកគ្នារវាងតួនាទីរបស់ក្រុមសមាជិកសភា (គណបក្ស Fraction) អ្នកឯកទេសផ្នែកទំនាក់ទំនង (អង្គភាពព័ត៌មាននយោបាយ ឬ PPUs) និងមន្ត្រីគណបក្សនយោបាយ (PUs) ដែលធំជាង។

*គោលបំណងចម្បងរបស់ PPU គឺត្រូវរក្សាសំណុំឯកសាររបស់បក្ស ធ្វើទំនាក់ទំនងដោះស្រាយវិបត្តិ បង្កើតយុទ្ធសាស្ត្រនិងបច្ចេកទេស និងបន្តទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ។*

PPUs ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅតាមតម្រូវការរបស់អ្នកនាំពាក្យគណបក្ស (សូមមើលផ្នែកបន្ទាប់) ដែលទទួលបានការគាំទ្រពីក្រុមអ្នកឯកទេសទំនាក់ទំនងសាធារណៈ (PR)។ តួនាទីរបស់ពួកគេ គឺត្រូវសម្របសម្រួលឲ្យមានលំហូរព័ត៌មានប្រចាំថ្ងៃពីក្រុមនយោបាយទៅក្រុមគោលដៅ (ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល)។ អ្នកនាំពាក្យអាចជាអ្នកអាជីព (មន្ត្រីផ្នែកទំនាក់ទំនងសាធារណៈអតីតអ្នកកាសែតជាដើម) ឬ មន្ត្រីជាន់ខ្ពស់របស់ក្រុម (ប្រធាន អនុប្រធាន)។ គោលបំណងចម្បងរបស់ PPU គឺត្រូវរក្សាសំណុំឯកសាររបស់បក្ស ធ្វើទំនាក់

ទំនងដោះស្រាយវិបត្តិ បង្កើតយុទ្ធសាស្ត្រនិងបច្ចេកទេស និងបន្តទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ។ ទាំងនេះពាក់ព័ន្ធទៅនឹងគណបក្សកាន់អំណាច មិនមែនក្រុមនយោបាយផ្សេងទៀត ដែលជាតំណាងរាស្ត្រក្នុងសភានោះទេ (គណបក្សប្រឆាំង)។

ខាងក្រោមគឺជាទំព័រតភ្ជាប់ទៅកាន់គេហទំព័រក្រុមនយោបាយមួយចំនួន ដើម្បីផ្តល់ជាឧទាហរណ៍ ថាតើក្រុមនយោបាយទាំងនេះមានលក្ខណៈដូចម្តេច ហើយតើក្រុមទាំងនេះធ្វើអ្វីខ្លះ។

- ក្រុមគណបក្សប្រជាជនអឺរ៉ុប (European People's Party) គឺជាកម្លាំងនយោបាយចម្រុះដែលមានអ្នកនិយមកណ្តាល និងពាក់កណ្តាលស្តាំនិយមគាំទ្រអឺរ៉ុប មកពីបណ្តាប្រទេសជាសមាជិកសហភាពអឺរ៉ុប។ ក្រុមគណបក្សនេះធ្វើការឆ្ពោះទៅសម្រេចគោលដៅដែលធ្វើឲ្យអឺរ៉ុបក្លាយជាតំបន់មួយ កាន់តែប្រកួតប្រជែង និងមានលក្ខណៈប្រជាធិបតេយ្យ ដើម្បីខិតចូលឲ្យកាន់តែកៀកពលរដ្ឋរបស់ខ្លួន និងបង្កើតឲ្យមានសេដ្ឋកិច្ចទីផ្សារសង្គម។ EPP គឺជាគណបក្សនយោបាយឆ្លងដែនដំបូងបំផុត ដែលត្រូវបានបង្កើតឡើងនៅកម្រិតអឺរ៉ុប ខណៈដែល EPP Group នាពេលបច្ចុប្បន្នគឺជាកម្លាំងនយោបាយធំបំផុតមួយនៅសភាអឺរ៉ុប (www.eppgroup.eu/)។
- គណបក្សពលករអូស្ត្រាលី (Australian Labor Party) គឺជាគណបក្សមួយក្នុងចំណោមគណបក្សធំៗពីរនៅក្នុងប្រទេសអូស្ត្រាលី ចំណែកឯគណបក្សមួយទៀត គឺគណបក្សសេរីនិយម (Liberal Party) ដែលស្ថិតក្នុងរដ្ឋាភិបាលចម្រុះជាមួយគណបក្សស្តាំនិយម គឺគណបក្សជាតិ (National Party) ដែលតំណាងឲ្យស្រុកនៅតាមជនបទ (www.alp.org.au/)។
- គណបក្សអភិរក្សនិយម (Conservative Party) គឺជាគណបក្សរបស់រដ្ឋាភិបាលនៅក្នុងប្រទេសអង់គ្លេស។ គណបក្សនេះគ្រប់គ្រងដោយមានការគាំទ្រពីគណបក្សប្រជាធិបតេយ្យសេរីនិយម (Liberal Democrat Party) ដែល

តូចជាង។ គណបក្សប្រឆាំងគឺគណបក្សពលករ (Labor Party) (www.conservatives.com/)។

*ក្រុមសារព័ត៌មានរបស់គណបក្សដោះស្រាយបញ្ហាវិបត្តិសារព័ត៌មានជំនួសមុខឲ្យគណបក្ស និងទទួលខុសត្រូវលើទំនាក់ទំនងផ្ទៃក្នុងជាមួយសមាជិកគណបក្ស។*

ក្រៅពីក្រុមនយោបាយ គណបក្សនយោបាយនេះ នឹងប្រើប្រាស់នាយកផ្នែកទំនាក់ទំនងរបស់ខ្លួន និងក្រុម (អង្គភាពព័ត៌មាន) ឲ្យដំណើរការស្របគ្នាជាមួយនឹងក្រុមនយោបាយសភា ប៉ុន្តែមិនពាក់ព័ន្ធនឹងទំនាក់ទំនងប្រចាំថ្ងៃជាមួយប្រព័ន្ធផ្សព្វផ្សាយ និងសកម្មភាពផ្សេងទៀតជុំវិញសកម្មភាពនយោបាយនៅក្នុងសភាទេ។ ក្រុមសារព័ត៌មានរបស់គណបក្សដោះស្រាយបញ្ហាវិបត្តិសារព័ត៌មានជំនួសមុខឲ្យគណបក្ស និងទទួលខុសត្រូវលើទំនាក់ទំនងផ្ទៃក្នុងជាមួយសមាជិកគណបក្ស។ ការរៀបចំបក្សថ្នាក់តំបន់មួយចំនួន ប្រហែលជាត្រូវការអ្នកឯកទេសផ្នែកប្រព័ន្ធផ្សព្វផ្សាយ។

PU ត្រូវរក្សាទំនាក់ទំនងផ្ទៃក្នុងជាប្រចាំរវាងក្រុមនយោបាយសភា PPU។ កត្តានេះគួរតែមានការសម្របសម្រួលតាមរយៈគណៈកម្មាធិការមួយ ដែលដឹកនាំដោយប្រធានទីប្រឹក្សាផ្នែកប្រព័ន្ធផ្សព្វផ្សាយរបស់បក្ស តាមរយៈកិច្ចប្រជុំប្រចាំថ្ងៃរបស់អ្នកឯកទេសខាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់នៅក្នុងសភា។ ការងារនេះត្រូវអនុវត្តដោយគណបក្សនយោបាយកាន់អំណាចតែមួយប៉ុណ្ណោះ មិនមែនក្រុមនយោបាយផ្សេងទៀតនៅក្នុងសភា (គណបក្សប្រឆាំង) នោះទេ។

## ៦. ឧបករណ៍របស់អង្គភាពព័ត៌មាននយោបាយ

ឧបករណ៍ទំនាក់ទំនងរបស់ PPU រួមមានការរៀបចំផែនការ ការសម្របសម្រួល និងវេទិកាយុទ្ធសាស្ត្រ ដោយមានទំនាក់ទំនងប្រចាំថ្ងៃ ជាពិសេសជាមួយសារព័ត៌មាន ដែលជាចំណុចផ្តោតដ៏សំខាន់មួយ។ PPU នឹងទទួលខុសត្រូវលើការចែកចាយ ការដោះស្រាយនឹងសំណួររបស់សារព័ត៌មាន និងប្រតិកម្មផ្សេងៗទៀត។

ឧបករណ៍ដែល PPU ប្រើប្រាស់រួមមាន៖

- គេហទំព័រមួយផ្តោតជាពិសេសលើប្រព័ន្ធផ្សព្វផ្សាយ។ គេហទំព័រនេះគួររួម

បញ្ចូលទំព័រ "មានអ្វីថ្មី" ដែលមានព័ត៌មានថ្មីៗ និងឈ្មោះមន្ត្រីទំនាក់ទំនងសំខាន់ៗ សម្រាប់ធ្វើទំនាក់ទំនង។

- មូលដ្ឋានទិន្នន័យសារព័ត៌មានសម្រាប់ការចែកចាយតាមអ៊ិនធើណិត។
- ខិត្តប័ណ្ណព័ត៌មានអេឡិចត្រូនិចមួយ ដែលផ្សព្វផ្សាយព័ត៌មានថ្មីៗ ស្តីពីបញ្ហាសំខាន់ៗ
- កម្មវិធីទូរស័ព្ទទំនើប (Smartphone)
- ទំព័រ Facebook និងគណនី Twitter
- បណ្ណុំប្រព័ន្ធផ្សព្វផ្សាយជាទម្រង់ឯកសាររឹង សម្រាប់បញ្ចូលក្នុងការចេញផ្សាយព័ត៌មាន អត្ថបទពិសេស (Features) ព័ត៌មានសាវតារ
- អង្គចងចាំ (Memory stick) របស់កុំព្យូទ័រមួយ ដែលមានផ្ទុកអត្ថបទពីប្រព័ន្ធផ្សព្វផ្សាយ និងរូបភាពធំច្បាស់ ដើម្បីយកដាក់ក្នុងកាសែត និងទស្សនាវដ្តី (ទំហំតូចបំផុត ១ មេកាបៃ)។
- គួរតែរក្សាទុកបណ្ណាល័យរូបថត និងវីដេអូ។
- សន្និសីទកាសែត សេចក្តីអធិប្បាយសង្ខេប បទសម្ភាសមួយទល់នឹងមួយ សេចក្តីអធិប្បាយសង្ខេប "ដោយមិនបានថត ឬកត់ត្រាទុក"។
- ឧបករណ៍ដែលប្រើប្រាស់ គួរបញ្ចូលទស្សនៈរបស់គណកម្មាធិការសម្របសម្រួលទំនាក់ទំនងខាងក្រៅ (CCCC: Cross Communications Cordinating Committee) តួនាទីចំបងរបស់គណកម្មការនេះគឺ សម្របសម្រួលទំនាក់ទំនងនយោបាយទាំងអស់របស់គណបក្សជារៀងរាល់អាទិត្យ។
- កិច្ចប្រជុំជារៀងរាល់សប្តាហ៍របស់អ្នកជំនាញផ្នែកទំនាក់ទំនងទាំងអស់ នៅក្នុងសភា (និងមកពីទីស្នាក់ការកណ្តាលរបស់បក្សតាមការតម្រូវ) ដើម្បីជានាអំពីការសម្របសម្រួលសារ។
- ការប្រើប្រាស់ "ប្រព័ន្ធទំនាក់ទំនង" ដើម្បីពិនិត្យនិងតាមដានទីតាំងរបស់នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីសំខាន់ៗជារៀងរាល់សប្តាហ៍។ ប្រព័ន្ធទំនាក់ទំនងអាចជាប្រព័ន្ធប្រចាំសប្តាហ៍ ដែលបង្ហាញពីព័ត៌មានទំនាក់ទំនងដែលពាក់ព័ន្ធ

ទាំងអស់។ ឧទាហរណ៍ៈ ការធ្វើដំណើររបស់នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ ព្រឹត្តិការណ៍នយោបាយសំខាន់ៗ នៅពេល ខាងមុខជាដើម ដែលអាចត្រូវការ មធ្យោបាយទំនាក់ទំនង

- មើលការខុសត្រូវលើឧបករណ៍ដែល PU និងទីប្រឹក្សាសារព័ត៌មានរបស់រដ្ឋមន្ត្រី គួរប្រើប្រាស់ ដើម្បីយល់ដឹងអំពីគោលនយោបាយរបស់គណបក្ស ឬដើម្បី ឆ្លើយតបនឹងបញ្ហាបន្ទាន់។ ឧទាហរណ៍ ដើម្បីរៀបចំសន្និសីទមួយ ដែលទទួល បានការផ្សព្វផ្សាយយ៉ាងទូលំទូលាយបំផុត ឬ ដើម្បីផ្តល់ព័ត៌មាន និងកិច្ច សម្ភាស៍មួយនឹងមួយ។ ចរិតលក្ខណៈនៃបញ្ហានេះ មិនថាជាលក្ខណៈផ្តួចផ្តើម ឬឆ្លើយតប នឹងកំណត់ថាតើឧបករណ៍ណា ដែលត្រូវប្រើប្រាស់។
- ពិនិត្យតាមដានឲ្យបានជិតដល់លើបញ្ហាដែលកំពុងកើតឡើង និងមើលការ ខុសត្រូវលើការរៀបចំឆ្លើយតប ប្រសិនបើចាំបាច់ (ទំនាក់ទំនងដោះស្រាយ វិបត្តិ)។
- រៀបចំផែនការទំនាក់ទំនងដោះស្រាយវិបត្តិមួយ។ អ្នកនាំពាក្យ (ចូរមើលផ្នែក ខាងក្រោម) នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ ប៉ុន្តែ CCCC នឹងត្រូវ មើលការខុសត្រូវលើប្រភេទនៃសារដែលនឹងត្រូវបង្កើតឡើង។

## ៧. ទំនាក់ទំនង/ទំនាក់ទំនងសាធារណៈនៃសមាជិកសភាម្នាក់ៗ

*រដ្ឋលេខាធិការដ្ឋានគួរតែជួលទីប្រឹក្សាខាងក្នុង (សម្រាប់ហេតុផលសន្តិសុខ) ដើម្បីផ្តល់ប្រឹក្សាដល់សមាជិកសភាដែលត្រូវការជំនាញបែបនេះ ដើម្បីបង្កើតគេហទំព័ររបស់ខ្លួន។*

សមាជិកសភាគឺជាអ្នកទំនាក់ទំនងមុនគេដែលជួនកាល សមត្ថភាពក្នុងការបញ្ជូន សារវិជ្ជមានរបស់ពួកគេអាចត្រូវបានមើលរំលង។ ពួកគេមានទំនាក់ទំនងផ្ទាល់ជា ទៀងទាត់ជាមួយម្ចាស់ឆ្នោតនៅមណ្ឌលរបស់ពួកគេ និងអាចធ្វើឲ្យព័ត៌មានគ្រប ដណ្តប់យ៉ាងទូលំទូលាយនៅក្នុងមណ្ឌលដែលខ្លួនតំណាង។ ពួកគេ គឺជាមធ្យោ បាយទំនាក់ទំនងដ៏សំខាន់សម្រាប់ព័ត៌មានរវាងសាធារណជន និងគណបក្ស របស់ខ្លួន (ឧទាហរណ៍ រវាងអង្គការសង្គមស៊ីវិល NGOs ស្ថាប័នអាជីព ក្រុម សាសនា និងអាជ្ញាធរតាមមូលដ្ឋាន) និងជាអ្វីដែលសារព័ត៌មានសង្គមសព្វថ្ងៃ

តាមដាននៅក្នុងឃុំរបស់ខ្លួន ឬនៅថ្នាក់ស្រុក និងខេត្ត។ ឧបករណ៍ទំនាក់ទំនងដែលសមាជិកសភាអាចប្រើប្រាស់បានរួមមាន៖

- ការបង្កើតគេហទំព័រមួយសម្រាប់ខ្លួនឯង ហើយប្រសិនបើអាចរួមទាំងប្លក់មួយផង។
- សមាជិកសភានីមួយៗនឹងត្រូវការការគាំទ្រពីរដ្ឋលេខាធិការដ្ឋាន ដើម្បីបង្កើតគេហទំព័រ។ រដ្ឋលេខាធិការដ្ឋានគួរតែជួលទីប្រឹក្សាខាងក្នុង (សម្រាប់ហេតុផលសន្តិសុខ) ដើម្បីផ្តល់ប្រឹក្សាដល់សមាជិកសភាដែលត្រូវការជំនាញបែបនេះ ដើម្បីបង្កើតគេហទំព័ររបស់ខ្លួន។ រដ្ឋលេខាធិការដ្ឋានត្រូវធ្វើការជួយសមាជិកសភាក្នុងការមើលថែទាំគេហទំព័រនេះ។ ខ្លឹមសារក្នុងគេហទំព័រគួរតែរួមមាន៖
  - នៅលើទំព័រដើម៖ សេចក្តីណែនាំអំពីសមាជិកសភា ដោយមានរូបថតមួយសន្លឹក (ជាមួយគ្រួសារ បើមានបំណងធ្វើដូច្នេះ)
  - តំណភ្ជាប់ទៅកាន់សុន្ទរកថា សេចក្តីផ្សាយព័ត៌មាន អត្ថបទពិសេស។
  - មានផ្នែកវីដេអូ និងរូបថត។ វីដេអូពី YouTube ប្រសិនបើពាក់ព័ន្ធ និងសមរម្យ។
  - តំណភ្ជាប់ទៅកាន់ព័ត៌មាន
  - លើសពីនេះ៖ រូបថតនៅលើទំព័រនីមួយៗ
- បង្កើតមុខមាត់នៅចំពោះមុខសារព័ត៌មាន ដោយជួបជាមួយសារព័ត៌មានក្នុងមូលដ្ឋានជាប្រចាំដើម្បីធ្វើបទសម្ភាសន៍ សង្ខេបព័ត៌មាន ឬគ្រាន់តែជួបជុំគ្នាក្នុងសង្គមធម្មតាតែប៉ុណ្ណោះ។
- ការជួបប្រជុំជាញឹកញាប់ជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ នៅក្នុងតំបន់របស់ពួកគេ ដើម្បីយល់ដឹងអំពីការសម្រេចចិត្តរបស់គណបក្ស។
- បង្កើតមូលដ្ឋានទិន្នន័យមួយអំពីអ្នកចូលមើលសំខាន់ៗ។
- ចែកចាយព្រឹត្តិបត្រអេឡិចត្រូនិចជាប្រចាំតាមរយៈមូលដ្ឋានទិន្នន័យ
- សារព័ត៌មានក្នុងតំបន់ និងកិច្ចសម្ភាស៍តាមវិទ្យុអំពីបញ្ហានានា តាមការចាំបាច់។

*បង្កើតមុខមាត់នៅចំពោះមុខសារព័ត៌មាន ដោយជួបជាមួយសារព័ត៌មានក្នុង មូលដ្ឋានជាប្រចាំដើម្បីធ្វើបទសម្ភាសន៍ សង្ខេបព័ត៌មាន ឬគ្រាន់តែជួបជុំគ្នាក្នុងសង្គមធម្មតាតែប៉ុណ្ណោះ។*

- ផ្សព្វផ្សាយរបាយការណ៍ព័ត៌មានតាមវិទ្យុជារៀងរាល់សប្តាហ៍ អំពីព្រឹត្តិការណ៍នានានៅមណ្ឌលដែលខ្លួនតំណាង និងជូនដំណឹងដល់សាធារណជនអំពីនិមិត្តសញ្ញាជាតិ។
- សរសេរអត្ថបទព័ត៌មានប្រចាំសប្តាហ៍ ឬខែនៅក្នុងកាសែតតាមមូលដ្ឋានដើម្បីជូនដំណឹងដល់សាធារណជនអំពីបញ្ហាសំខាន់ៗ ដែលមណ្ឌលសភាខ្លួនជួបប្រទះ។
- ប្រសិនបើគ្មានកាសែតទេ ចូរចែកខិត្តប័ណ្ណឲ្យទៀងទាត់ក្នុងនាមជាសមាជិកសភាផ្ទាល់ តាមរយៈការចែកខិត្តប័ណ្ណ ការិយាល័យមូលដ្ឋានរបស់សមាជិកសភា និងបណ្តាញអ្នកធ្វើការក្នុងបក្សរបស់ខ្លួន។
- ទំព័រហ្វេសប៊ុក (Facebook Page)
- គេហទំព័រមួយ រួមមានប្លក់មួយ។ គេហទំព័រនេះអាចមានវីដេអូដែលសមរម្យពី YouTube។
- រៀបចំកិច្ចប្រជុំ "សាលាក្រុង" ជាទៀងទាត់ ហើយសាធារណជនត្រូវបានអញ្ជើញសម្រាប់វគ្គសំណួរ-ចម្លើយ។
- កិច្ចប្រជុំទៀងទាត់ជាមួយអ្នកធ្វើការសម្រេចចិត្តក្នុងតំបន់ រួមមានឥស្សរជនធុរកិច្ចឈានមុខ។
- បង្កើតចលនា "យុវជន" របស់គណបក្សក្នុងចំណោមម្ចាស់ឆ្នោតរបស់ខ្លួនដើម្បីអប់រំម្ចាស់ឆ្នោតជាយុវជនដែលមានសក្តានុពល អំពីដំណើរការ និងប្រព័ន្ធសភា/នយោបាយ។
- ការចែកចាយខិត្តប័ណ្ណ កូនសៀវភៅព័ត៌មាន និងសម្ភារបោះពុម្ពផ្សេងៗទៀត។
- កិច្ចប្រជុំទៀងទាត់ជាមួយថ្នាក់ដឹកនាំក្នុងភូមិ។
- ការបង្កើតព្រឹត្តិការណ៍សង្គម និងអញ្ជើញអ្នកធ្វើការក្នុងបក្ស ម្ចាស់មូលនិធិសារព័ត៌មាន និងសមាជិករបស់សង្គមស៊ីវិលដែលត្រូវបានជ្រើសរើស។ ព្រឹត្តិការណ៍នេះអាចពាក់ព័ន្ធនឹងគណបក្ស ឬជាព្រឹត្តិការណ៍សង្គមទាំងស្រុង ដូចជាកីឡា ឬការសម្តែងវប្បធម៌។

## ៨. ការផ្លាស់ប្តូរព័ត៌មានរបស់សមាជិកសភាជាមួយនឹងគណបក្សនយោបាយ

ការទទួលខុសត្រូវរបស់សមាជិកសភា ក្នុងការថែរក្សាជាតុចូលទៅក្នុងគណបក្ស រួមមានការអភិវឌ្ឍប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុង ដែលផ្តល់ប្រយោជន៍ដល់អង្គភាពទាំងពីរ។ ផលប្រយោជន៍ដ៏សំខាន់ ដែលសមាជិកសភាទទួលបាននៅក្នុងចំណុចនេះគឺការភ្ជាប់ទំនាក់ទំនងក្នុងមូលដ្ឋាន។ មតិកែលម្អរបស់សមាជិកសភាអាចរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់គណបក្សនយោបាយ ប្រសិនបើមតិទាំងនេះអាចជឿទុកចិត្តបាន និងមានសង្គតិភាព។ ការគាំទ្រគោលនយោបាយរួមរបស់គណបក្ស ក្នុងការចែកចាយព័ត៌មានក្នុងតំបន់ ពិតជាមានសារៈសំខាន់។ សមាជិកសភាដែលជាជួរមុខរបស់គណបក្សនឹងត្រូវកោះហៅ ដើម្បីទាក់ទាញមតិគាំទ្រ និងការពារគោលនយោបាយបែបនេះ។ ឧបករណ៍ទំនាក់ទំនងមួយចំនួន ដែលសមាជិកសភាអាចប្រើប្រាស់ក្នុងសកម្មភាពនេះរួមមាន៖

*មតិកែលម្អរបស់សមាជិកសភាអាចរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់គណបក្សនយោបាយ ប្រសិនបើមតិទាំងនេះអាចជឿទុកចិត្តបាន និងមានសង្គតិភាព។*

- រៀបចំព្រឹត្តិការណ៍នៅក្នុងមណ្ឌលសភារបស់ខ្លួន ដោយអញ្ជើញនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីពាក់ព័ន្ធ។ ព្រឹត្តិការណ៍ទាំងនេះអាចជាការបើកសម្ពោធស្ពានឬមន្ទីរពេទ្យ។
- ជានាថា គណៈអធិបតីដែលអញ្ជើញមកមានកម្មវិធីពេញលេញក្នុងការជួបជាមួយអ្នកធ្វើការក្នុងគណបក្ស អ្នករៃអង្គាស អ្នកឧបត្ថម្ភ និងអ្នកគាំទ្រក្នុងអំឡុងដំណើរទស្សនកិច្ចនេះ។ ការធ្វើដូច្នេះជាការសម្តែង "ការគួរសម" មួយដល់ប្រជាជនទាំងនោះ ប៉ុន្តែក៏ជាឱកាសសម្រាប់គណៈអធិបតីទទួលបានមតិកែលម្អដោយផ្ទាល់ពីមូលដ្ឋាន។
- ចេញផ្សាយព័ត៌មានជុំវិញដំណើរទស្សនកិច្ចនេះ និងអញ្ជើញក្រុមសារព័ត៌មានក្នុងស្រុកធ្វើការផ្សព្វផ្សាយ ដើម្បីឲ្យអ្នកដទៃអាចដឹងឮនិងកោតសរសើរអំពីអ្វីដែលសមាជិកសភា និងគណបក្សកំពុងតែធ្វើសម្រាប់មណ្ឌលសភារបស់ខ្លួន។
- ស្រដៀងគ្នានេះដែរ រៀបចំព្រឹត្តិការណ៍សង្គមមួយសម្រាប់ក្រុមការងារក្នុងគណបក្ស និងអ្នកឧបត្ថម្ភ ដើម្បីថ្លែងអំណរគុណដល់ពួកគេ និងទទួលបាន

"ព័ត៌មានសម្ងាត់" ស្ដីពីបញ្ហាក្នុងតំបន់ សម្រាប់ជាធាតុចូលទៅក្នុងល្បាយទំនាក់ទំនងរបស់គណបក្ស។

- រៀបចំ "កិច្ចប្រជុំតូចៗក្នុងបក្ស" របស់សមាជិកសភាមកពីខេត្តនៅក្បែរនិងនៅក្នុងសភា ដើម្បីដើរតួជាអ្នកទាក់ទាញមតិគាំទ្រលើបញ្ហានានា ក្នុងតំបន់របស់ខ្លួន។ កិច្ចប្រជុំតូចៗនៅក្នុងបក្ស គឺជាការជួបជុំរបស់សមាជិកសភាជាប្រចាំជាធម្មតាគឺជារៀងរាល់អាទិត្យ ដើម្បីពិភាក្សាបញ្ហា និងគោលនយោបាយ
- រួមចំណែកផ្ដល់ "មតិ" សម្រាប់បញ្ចូលក្នុងព័ត៌មានរបស់គណបក្សស្ដីពីប្រធានបទ ដែលគួរឲ្យចាប់អារម្មណ៍ជាក់លាក់ណាមួយ។ សកម្មភាពនេះអាចរួមមានការរួមចំណែកក្នុងប្លក់មួយដែលនៅលើគេហទំព័ររបស់គណបក្ស។
- ផ្ដល់របាយការណ៍ដល់គណបក្សអំពីឋានានុក្រមនៃព្រឹត្តិការណ៍ខាងមុខ បញ្ហាដែលកើតចេញពីមណ្ឌលសភារបស់សមាជិកសភា ដើម្បីជាធាតុចូលក្នុងប្រព័ន្ធទំនាក់ទំនង និងដំណើរការនៃការបង្កើតគោលនយោបាយ។ របាយការណ៍នេះអាចធ្វើបានតាមរយៈអ៊ីម៉ែល របាយការណ៍ជាលាយលក្ខណ៍អក្សរ ឬការជួបមុខគ្នាផ្ទាល់នៅសភា។
- បង្ហោះរបាយការណ៍ស្ដីពីព្រឹត្តិការណ៍ និងបញ្ហាថ្មីៗនៅក្នុងមណ្ឌលដែលខ្លួនតំណាង ដែលបច្ចុប្បន្នសមាជិកសភានោះកំពុងតែដោះស្រាយ នៅលើគេហទំព័ររបស់ពួកគេ។
- បង្កើតក្រុមអ៊ីម៉ែល ឬបន្ទប់ពិភាក្សាលើគេហទំព័រមួយ ដើម្បីឆ្លើយសំណួរ។ ផ្ដល់មតិកែលម្អលើ "ព័ត៌មានសម្ងាត់" ដែលពាក់ព័ន្ធដល់ PPU វិញ ដើម្បីឲ្យពួកគេដឹងអំពីការតាមដានបញ្ហា ដែលអាចមានសមាសធាតុទំនាក់ទំនងរបស់គណបក្សផងដែរ។

## ៩. តួនាទីរបស់អ្នកនាំពាក្យគណបក្ស

ការតែងតាំងអ្នកនាំពាក្យគណបក្ស ជាផ្នែកដ៏សំខាន់មួយនៃល្បាយទំនាក់ទំនង។ រដ្ឋាភិបាល ឬសមាជិកសភានីមួយៗ អាចជឿទុកចិត្តបានឬមិនបាន គឺអាស្រ័យ

លើការប្រព្រឹត្តរបស់បុគ្គលនោះ។ នៅគ្រប់ករណីទាំងអស់ អ្នកនាំពាក្យដែលត្រូវបានជ្រើសតាំងត្រូវមានលក្ខណៈដូចជា អាចទុកចិត្តបាន ជឿជាក់បាន មិនឆេវឆាវ មានភាពក្លាហាន រួសរាយ មានបទពិសោធន៍ និងជាអ្នកគ្រប់គ្រងល្អ។ ជារៀងរាល់ថ្ងៃ តួនាទីចម្បងរបស់អ្នកនាំពាក្យដែលត្រូវបានជ្រើសរើស គឺធ្វើឲ្យគណបក្សមានរូបភាពល្អបំផុត ក្នុងទំនាក់ទំនងសាធារណៈតាមដែលអាចធ្វើបាន។ អ្នកស្តាប់ចំបងគឺអ្នកសារព័ត៌មាន និងបណ្តាញព័ត៌មានដែលកំពុងមានកំណើន។ ក្នុងករណីរដ្ឋាភិបាល និងគណបក្ស អ្នកនាំពាក្យអាចមានលក្ខណៈខុសៗគ្នាអាស្រ័យលើបញ្ហាជាក់ស្តែង។ នៅក្នុងយុត្តាធិការខ្លះ ដូចជានៅវេសថ៍មីនីស្ទ័រ នៅចក្រភពអង់គ្លេស អ្នកនាំពាក្យត្រូវបានចាត់ចែងឲ្យធ្វើការលើប្រធានបទជាក់លាក់ ប៉ុន្តែក្នុងករណីនៅកម្ពុជា មានអ្នកនាំពាក្យពីរ ឬបីនាក់គឺស័ក្តិសមសម្រាប់ស្ថានភាពជាក់ស្តែង។ ទោះជាកត្តាដែលសំខាន់គឺសង្គតិភាពនៃសារក៏ដោយ ក៏អ្វីដែលសំខាន់ដែរនោះ គឺភាពប៉ិនប្រសប់របស់អ្នកនាំសារ។ កត្តានេះជួយបង្កើតភាពជឿទុកចិត្តជាសាធារណៈ។

*អ្នកស្តាប់ចំបងគឺអ្នកសារព័ត៌មាន និងបណ្តាញព័ត៌មានដែលកំពុងមានកំណើន*

## តួនាទីអ្នកនាំពាក្យរួមមាន៖

- សមត្ថភាពក្នុងការពិនិត្យតាមដានបញ្ហា និងរៀបចំក្រុមជុំវិញការឆ្លើយតប ឬសកម្មភាពផ្តួចផ្តើម។
- សហការជាមួយគ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល ដើម្បីសម្របសម្រួលដល់ទំនាក់ទំនងសាធារណៈនៅក្នុងជួររដ្ឋាភិបាល ក្រសួង ហើយបើចាំបាច់ ជំនួសឲ្យសមាជិកសភានីមួយៗ
- បង្កើតសារដ៏ត្រឹមត្រូវ ដោយសហការជាមួយភាគីផ្សេងៗទៀត
- ជាអ្នកបញ្ជូនសារដ៏គួរឲ្យទុកចិត្តមួយរូប
- បង្កើតផែនការ ដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ ដល់សារព័ត៌មាននិងសាធារណជន

- អាចកាត់បន្ថយផលប៉ះពាល់ឲ្យបានទាបបំផុត នៅពេលមានបញ្ហាបន្ទាន់/វិបត្តិ។

## តួនាទីប្រចាំថ្ងៃរបស់អ្នកនាំពាក្យគួរតែរួមមាន៖

- ចាប់ផ្តើមលឿន ពិនិត្យឡើងវិញនូវសារព័ត៌មានបន្ទាន់ទាំងអស់ និងជ្រើសរើសបញ្ហាគន្លឹះៗ ដែលអាចត្រូវការការឆ្លើយតប។
- រៀបចំកិច្ចប្រជុំជាមួយអ្នកធ្វើការនៅព្រឹកព្រលឹម ដើម្បីសម្រេចលើសកម្មភាពឆ្លើយតប ឬផ្តួចផ្តើម ។
- ការផ្លាស់ប្តូរព័ត៌មានជាមួយសមាជិក CCCC ជាពិសេសប្រធាន (ប្រសិនបើមិនមែនជាប្រធានដោយខ្លួនឯង) ទីស្តីការគណៈរដ្ឋមន្ត្រី។
- បង្កើតសារសំខាន់ៗ
- វាយតម្លៃថាតើទម្រង់នៃការរួមចំណែកដល់ការទំនាក់ទំនងណា ដែលត្រូវប្រើប្រាស់៖ សន្និសីទកាសែត ការចេញផ្សាយព័ត៌មាន សម្ភាស ការឆ្លើយតបទៅកាន់សំណួរសារព័ត៌មានតាមទូរស័ព្ទ។

## ការពិពណ៌នាអំពីការងារ

- គោលបំណងសំខាន់របស់អ្នកនាំពាក្យ គួរតែជាការអាចជឿជាក់បាន។ អ្នកដែលស័ក្តិសមជាអ្នកនាំពាក្យគួរតែ៖
- មានប្រវត្តិការងារខាងសារព័ត៌មានច្រើន អាចធ្វើការជាអ្នកកាសែតចន្លោះពី ៥ ទៅ ៧ ឆ្នាំ
- មានជំនាញនិយាយ និងសរសេរខ្លាំង
- ជាសមាជិកជាន់ខ្ពស់របស់គណបក្ស ដោយយល់ដឹងច្បាស់លាស់អំពីដំណើរការ គោលនយោបាយគណបក្ស ជាដើម
- មានបទពិសោធន៍ពីមុនជាអ្នកមើលការខុសត្រូវក្រុម
- យល់ដឹងអំពីសារព័ត៌មានអន្តរជាតិ ជាពិសេសទីភ្នាក់ងារព័ត៌មានសកល

- មានសមត្ថភាពក្នុងការកំណត់ឱកាសទំនាក់ទំនង និងបង្កើតកម្មវិធីគាំទ្រ
- ពូកែខាងកុំព្យូទ័រ
- យល់ដឹងអំពីប្រតិបត្តិការនៃសារព័ត៌មានសង្គម និងវដ្តព័ត៌មាន២៤ម៉ោង
- មានភាពចាស់ទុំ មើលទៅគួរឲ្យជឿទុកចិត្ត
- មានសមត្ថភាពក្នុងការចាប់យកការពិតបានយ៉ាងឆាប់រហ័ស និងប្រមូលផ្តុំការពិតទាំងនោះសម្រាប់ការប្រើប្រាស់របស់សាធារណជន
- មានជំនាញគ្រប់គ្រង និងជំនាញគិតប្រកបដោយយុទ្ធសាស្ត្ររឹងមាំ
- មានភាពស្ងប់ស្ងៀមនៅពេលមានសម្ពាធ
- មានការអត់ធ្មត់ ចេះលេងសើច។

## ១០.ទំនាក់ទំនងផ្ទៃក្នុងជាមួយក្រុមនយោបាយ

នៅក្នុងទំនាក់ទំនងផ្ទៃក្នុងជាមួយក្រុមនយោបាយនានា អ្នកនាំពាក្យគួរតែខិតខំប្រឹងប្រែងដើម្បីរក្សាអព្យាក្រឹត្យភាពតាមដែលអាចធ្វើបាន។ នយោបាយប្រកាន់បក្សពួករបស់អ្នកនាំពាក្យ ដែលមិនជ្រើសចេញពីការបោះឆ្នោត (ចាត់តាំង) នឹងបំផ្លាញនូវភាពជឿទុកចិត្តរបស់ពួកគេ។ ប្រសិនបើអ្នកនាំពាក្យគឺជាអ្នកនយោបាយ គាត់ប្រហែលជាចង់លេងល្បែងនយោបាយ ប៉ុន្តែអ្វីដែលចាំបាច់បំផុត គឺអ្នកនាំពាក្យម្នាក់ត្រូវបានមើលឃើញថា ជាបុគ្គលដែលមើលពីសំបកក្រៅគួរឲ្យគោរព ជឿទុកចិត្ត និងមិនប្រកាន់បក្សពួក។ ប្រសិនបើអ្នកនាំពាក្យដែលចាត់តាំងប្រឡូកក្នុងនយោបាយ និងចូលបក្សសម្ព័ន្ធជាមួយក្រុមមួយជាជាងក្រុមមួយទៀត ភាពជឿទុកចិត្តរបស់គាត់ត្រូវបាត់បង់។

*ប្រសិនបើអ្នកនាំពាក្យដែលចាត់តាំង ប្រឡូកក្នុងនយោបាយ និងចូលបក្សសម្ព័ន្ធជាមួយក្រុមមួយជាជាងក្រុមមួយទៀត ភាពជឿទុកចិត្តរបស់គាត់ត្រូវបាត់បង់។*

ដើម្បីកាត់បន្ថយបញ្ហានេះ អ្នកនាំពាក្យគួរតែធ្វើជាអធិបតីក្នុងកិច្ចប្រជុំយ៉ាងទៀតទាត់ ដោយផ្តោតលើតែទំនាក់ទំនងខាងក្នុង ឬខាងក្រៅ ដោយមានវត្តមានតំណាងរបស់ក្រុម ដែលអាចពិភាក្សាពីយុទ្ធសាស្ត្រនយោបាយ ប៉ុន្តែតាមរយៈការធ្វើជាអធិបតីនេះ អ្នកនាំពាក្យគួរតែរក្សាអព្យាក្រឹតភាពរបស់គាត់។

## ១១. ទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ

គណបក្សនយោបាយ និងសភាខ្លួនឯងត្រូវការទំនាក់ទំនងខាងក្រៅប្រកបដោយប្រសិទ្ធភាពជាមួយសង្គមស៊ីវិលនៅគ្រប់ស្ថាប័ននានា ដើម្បីឲ្យប្រទេសប្រជាធិបតេយ្យអាស្រ័យសភាមួយសម្រេចកាតព្វកិច្ចរបស់ខ្លួន។ លើកលែងតែសារព័ត៌មាន ស្ថាប័នទាំងនេះមានទំនាក់ទំនងជាមួយៈ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ម្ចាស់ជំនួយ វិនិយោគិន អ្នកផ្ដល់មូលនិធិដល់គណបក្សនយោបាយ អង្គការថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុមវប្បធម៌ អប់រំ និងធុរកិច្ច។

## ១២. ទំនាក់ទំនងសភាជាមួយស្ថាប័នខាងក្រៅ

សភាជាស្នូលនៃប្រជាធិបតេយ្យ ដែលមានការទទួលខុសត្រូវពិសេសដើម្បីបន្តអប់រំផ្សព្វផ្សាយនៅក្នុងសង្គមកម្ពុជា។ សភានេះគួរតែត្រូវបានមើលឃើញថាជាស្ថាប័នផ្សារភ្ជាប់ទំនាក់ទំនងស្របច្បាប់រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល។ សភាក៏គួរតែជាស្ថាប័នអព្យាក្រឹតផងដែរ។

*សភាជាស្នូលនៃប្រជាធិបតេយ្យ ដែលមានការទទួលខុសត្រូវពិសេសដើម្បីបន្តអប់រំផ្សព្វផ្សាយនៅក្នុងសង្គមកម្ពុជា។*

ប្រការនេះអាចសម្រេចបានតាមរយៈ ៖

- ការប្រើប្រាស់គេហទំព័ររបស់សភាជាវិធីសាស្ត្រដ៏សំខាន់មួយ ដើម្បីអប់រំផ្សព្វផ្សាយដល់ស្ថាប័ននានា។
- ការបើកឱកាសដល់ការជជែកតាមអ៊ីនធើណិត ឬគេហទំព័រដើម្បីលើកទឹកចិត្តឲ្យមានទំនាក់ទំនងទៅវិញទៅមករវាងសភា និងស្ថាប័ន។
- បង្កើតក្រុមជាក់លាក់មួយ ដែលអាចឲ្យស្ថាប័នជួបជាមួយមន្ត្រីរដ្ឋសភាដើម្បីពិភាក្សាពីបញ្ហានានា។
- អញ្ជើញអង្គការដែលធ្វើការលើការកសាងសមត្ថភាពឲ្យចូលរួមក្នុងការអភិវឌ្ឍគម្រោង។
- បង្កើតក្រុមមួយ ដែលមានសមាសភាពស្ថាប័នពីខាងក្រៅសម្រាប់បញ្ហាអភិបាលកិច្ចល្អ។

# ADVISORY PAPERS ON POLITICAL PARTY DEVELOPMENT

## Volume II

Guidelines to Parliamentary Communications

Konrad Adenauer Stiftung

Freedom, justice and solidarity are the basic principles underlying the work of the Konrad-Adenauer-Stiftung (KAS). KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian-social, conservative and liberal traditions. His name is synonymous with the democratic reconstruction of Germany, the firm alignment of foreign policy with the trans atlantic community of values, the vision of a unified Europe and an orientation towards the social market economy. In our European and international cooperation with more than 70 offices abroad and projects in over 120 countries, we make a unique contribution to the promotion of democracy, the rule of law and a social market economy.

The office in Cambodia has been extablished in 1994. KAS in Cambodia is mainly operating in the following fields: Administrative Reform and Decentralization, Strenthening Political Parties and Parliaments, Legal Reform, Media Development, Political Education and Social Market Economy, as well as Foreign Policy Consultancy.

# Contents


Preface .......... 1

1. Introduction .......... 3

2. Parliament Administration's Communications Functions .......... 4

3. Distribution of Information: Key Tools .......... 8

4. Political Party (Groups) Communication in Parliament .......... 10

5. The Relationship between Parliamentary Group Press Units and the Political Press Units .......... 13

6. Political Press Unit Tools .......... 14

7. Communication / Public Relation of Individual Members of Parliament .......... 15

8. Member of Parliament Liaison with Political Parties .......... 17

9. The Role of the Party Spokesperson .......... 18

10. Internal Communication between Spokesman and Political Groups .......... 19

11. Communications with External Institutions .......... 20

12. Parliament External Institution Communications .......... 20

# Preface

